ម្ដាយ ! កូនលោកនាយករដ្ឋមន្ត្រី ប្រហែលជាមិនបានសប្បាយដូចចិត្តវាប៉ងទេមើលទៅយប់នេះ ។ ដូច្នេះ នៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់សូមអ្នកម្ដាយរៀបចំបាយទឹកឡើងយើងនឹងទទួលទាន” ។ ម្ដាយអាឡាដាំងក៏យល់ច្បាស់ថាកូនគាត់ នឹងទៅយកចង្កៀងមកប្រើការតាមដែលអាចធ្វើបាន ដើម្បីឱ្យការរៀបចំអាពាហ៍ពិពាហ៍កូនលោកនាយករដ្ឋមន្ត្រី និងព្រះនាងម្ចាស់ក្សត្រីអាចប្រព្រឹត្តទៅបានស្រួល តែត្រឹមពេលរៀបជប់លៀងអាហាររួច ។ យល់ដូច្នេះ គាត់ក៏នៅស្ងៀមអាឡាដាំងក៏ចូលទៅក្នុងបន្ទប់កាន់យកចង្កៀងទិព្វមកលាក់បំបាំងពីភ្នែកម្ដាយប្រយោជន៍កុំឱ្យគាត់មានសេចក្ដីតក់ស្លុត ក្រោយដែលបានឃើញរូបអារក្ស ។ បានចង្កៀងមកកាលណាបុរស ក៏យកទៅដុសនឹងដីត្រង់កន្លែងដែលដុសមុនៗ ជាបន្ទាន់ក៏លេចរូបអារក្សមកភ្លាមហើយក៏និយាយសួរទៅកាន់អាឡាដាំងថា : “តើលោកត្រូវការអ្វី? ខ្ញុំបាទមកនេះ ក្នុងឋានៈជាទាសីដើម្បីទទួលធ្វើតាមបង្គាប់លោក និងអំពីជនទាំងឡាយឯណាដែលមានចង្កៀងនេះនៅនឹងដៃ មិនតែប៉ុណ្ណេះ នៅមានអារក្សជាច្រើនទៀត ដែលមានភារៈដូចខ្ញុំបាទនេះដែរ ” ។

ចូរឯងប្រុងស្ដាប់ យើងនឹងអធិប្បាយប្រាប់ (អាឡាដាំងពោល) តាំងពីដើមរៀងរហូតមក ឯងតែងតែផ្ដល់របស់អ្វីមកឱ្យយើងបរិភោគចិញ្ចឹមជីវិត នៅពេលដែលត្រូវការ ។ ឥឡូវនេះ យើងមានការមួយសំខាន់ណាស់យើងចង់ឱ្យឯងបំពេញកិច្ចនេះ ឱ្យបានសម្រេចឱ្យយើង ។ ឯរឿងនេះដូចតទៅនេះ :



ពីថ្ងៃមុន យើងបានចូលទៅចែចូវ ដណ្ដឹងព្រះនាងបាឌ្រូលប៊ូឌួរជាព្រះរាជបុត្រីព្រះបាទស៊ុលតង់ ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ព្រះបាទស៊ុលតង់ ក៏យល់ព្រម តែសន្យានឹងយើងថា ចាំបីខែទៀតសិន ។ ឥឡូវមិនទាន់គ្រប់៣ខែផង ស្រាប់តែព្រះអង្គរៀបអភិសេកព្រះរាជ បុត្រីព្រះអង្គជាមួយនឹងកូនលោកនាយករដ្ឋមន្ត្រីឯណោះវិញធ្វើព្រងើយ ។ យើងទើបតែនឹងបានដឹងដំណឹងនេះ ហើយការនេះមានដូច្នេះពិតប្រាកដមែន ។ ព្រោះហេតុនេះ ការដែលយើងត្រូវឱ្យឯងធ្វើនោះ គឺនៅពេលដែលគូសង្សារថ្មីថ្មោងនេះដាក់ខ្លួនដល់គ្រែភ្លាម ចូរឯងទៅលើកសែងមនុស្សទាំងអស់ យកមកដាក់ឱ្យយើងត្រង់កន្លែងនេះ ។

- បាទលោកចៅហ្វាយ ! ខ្ញុំនឹងទទួលធ្វើតាម តើលោកមានការអ្វី នឹងបង្គាប់ខ្ញុំទៀតទេ (អារក្សឆ្លើយ) ។

- គ្មានការអ្វីទៀតទេ ឥឡូវនេះ (អាឡាដាំងតប) ។ មួយរំពេច អារក្សក៏អន្តរធានបាត់ទៅ ។

បន្ទាប់មក អាឡាដាំងក៏ចេញមកទទួលទានបាយជាមួយនឹងម្ដាយ ដោយមានឥរិយាបថនឹងនួនដូចធម្មតា ។ លុះអាស្រ័យបាយរួច បុរសក៏ជជែកលេងជាមួយម្ដាយអំពីរឿងអាពាហ៍ពិពាហ៍នេះ ធ្វើបែបហាក់ដូចជាគ្មានព្រួយបន្តិចសោះ ។ មួយសន្ទុះមក បុរសក៏ចូលទៅក្នុងបន្ទប់ទុកពេលឱ្យម្ដាយទទួលទានដំណេកដោយសេរី ។ ចំណែកខ្លួនបុរសវិញ អ្នកឥតទទួលទានដំណេកលក់ឡើយ ។ អ្នកទន្ទឹងចាំមើលផ្លូវ



អារក្ស ត្រឡប់មកពីបំពេញមុខងារតាមបង្គាប់ខ្លួន ។ ខណៈនោះ ក្នុងព្រះបរមរាជវាំងព្រះបាទស៊ុលតង់ គេមានរៀបចំតុបតែងប្រដាប់ប្រដាគ្រប់យ៉ាងអឹកធឹក ដើម្បីធ្វើកិច្ចមង្គលអភិសេកម្ចាស់ក្សត្រី ។ សាយណ្ហសម័យនោះប្រកបទៅដោយសេចក្ដីសប្បាយរីករាយជាអនេកប្បការរហូតដល់រាត្រីសម័យទើបចប់ ។ បុត្រលោកនាយករដ្ឋមន្ត្រីក្រោយដែលបានទទួលសញ្ញាពីនាយតម្រួត មនុស្សក្រៀវរបស់ព្រះនាងបា-ឌ្រូលប៊ូឌួរ ក៏ដកខ្លួនថយចេញពីទីប្រជុំមួយរំពេច ។ នាយតម្រួតក៏នាំបុត្រលោកនាយករដ្ឋមន្ត្រីតម្រង់ទៅព្រះរាជដំណាក់ព្រះនាងអគ្គមហេសីភ្លាមចូលរហូតទៅដល់ក្នុងបន្ទប់ ដែលមានគ្រែផ្ទំដំណេករៀបចំទុកជាស្រេច ។ បុរសក៏ចូលទៅគេងលើគ្រែនោះមុន ។ ក្រោយបន្តិចមក ព្រះបាទស៊ុលតាន ដោយមានស្រីស្នំដង្ហែមកផង ក៏នាំព្រះរាជបុត្រីចូលមក ។ ប៉ុន្តែជាធម្មតារបស់ស្ត្រីព្រហ្មចារីដែលពុំទាន់ស្គាល់រសជាតិនៃសេចក្ដីស្នេហា ផ្អែម ឬចត់នោះ ។ ព្រះនាងក៏ប្រកែកធ្វើប្លុកធ្វើពាង់ក់មិនព្រមចូលរួមសង្វាសជាមួយនឹងគូស្នេហា ។ ព្រះបាទស៊ុលតាន ជាព្រះវរមាតា ក៏ចាប់សម្រាតខោអាវព្រះនាង ហើយបង្ខំឱ្យព្រះនាងចូលទៅផ្ទំលើគ្រែ ។ រួចព្រះមហាក្សត្រិយានី ឱនថើបឱបរឹតព្រះរាជបុត្រីឱ្យពរសព្វសាធុការឱ្យព្រះនាងប្រកបដោយសេចក្ដី សុខសប្បាយក្នុងរាត្រីនេះ ទើបព្រះអង្គនិងពួកស្រីហែហមដកខ្លួនថយចេញ ។ ឯស្រីដែលចេញក្រោយគេ ក៏ឥតភ្លេចទាញបន្ទប់បិទឡើយ ។

ទាញទ្វារបិទស្ទើរតែពុំទាន់ហើយស្រួលផង  អារក្សជាទាសីមានភក្តីភាព  ចំពោះចង្កៀងទិព្វដែលតែងតែទទួលធ្វើតាមបង្គាប់ជនណា ដែលមានចង្កៀងនោះ ឥតល្អៀងឬច្រឡំប្រហែសខកខានម្តងណាសោះ  ក៏ចូលទៅលើកយកគ្រែនិងមនុស្សនៅលើនោះទៅដាក់នៅក្នុងបន្ទប់ផ្ទះអាឡាដាំងបាត់មួយរំពេច  ដោយឥតទុកពេលឱ្យគូស្នេហាថ្មីថ្មោងនេះលូកលាន់បិចបោច  ប្រលែងលេងជាមួយនឹងភរិយាថ្មីថ្មោងបានបន្តិចបន្តួចសោះឡើយ ។ ពោលដោយខ្លី ទៅគឺថាគូសង្សារថ្មីនេះមិនទាំងបានស្ទាបសាច់គ្នាផង ។ លុះកើតព្រឹត្តការណ៍ដូច្នេះឡើង អ្នកទាំងពីរក៏សែនឆ្ងល់ហួសប្រមាណ ។

ដំណាលពីអាឡាដាំង  ដែលទន្ទឹងចាំឱ្យតែអារក្សលើកគ្រែនិងមនុស្សនោះមកដល់ នឹងបំពេញបំណងរបស់ខ្លួន លុះអារក្សត្រឡប់មកវិញភ្លាម  អ្នកឥតបណ្តោយឱ្យកូនលោកនាយករដ្ឋមន្ត្រី  នៅដេកជាមួយនឹងព្រះនាងម្ចាស់ក្សត្រីឡើយ  បុរសបង្គាប់ទៅអារក្សភ្លាមថា: “ចូរឯងលើកយកបុរសទើបនឹងការថ្មីថ្មោងនេះ  ទៅដាក់ខ្ទប់ក្នុងបន្ទប់តូចមួយ  រួចស្អែកឡើងពីព្រលឹមមុនពេលថ្ងៃរះបន្តិច  ចូរឯងត្រឡប់មកវិញកុំខាន” ។  អារក្សក៏លើកកូនលោកនាយករដ្ឋមន្ត្រីចេញពីគ្រែដែលមានតែអាវមួយពាក់ជាប់នឹងខ្លួន  យកទៅដាក់ត្រង់កន្លែងដែលអាឡាដាំងប្រាប់ ។ ប៉ុន្តែមុននឹងដាក់ចូលទៅក្នុងកន្លែង អារក្សក៏ដកដង្ហើមធំមួយឃ្លូដាក់កូនលោកនាយករដ្ឋមន្ត្រី  បណ្តាលឱ្យបុរសភ័យញ័រ



អស់សព្វសព៌ាង្គកាយ ចាប់តាំងពីក្បាលរហូតដល់ចុងជើង ហើយពុំអាចរើចេញខ្លួនពីកន្លែងនោះបានឡើយ គឺត្រូវឈរជានិច្ច ។

ដោយអំណាចក្តីស្នេហារបស់អាឡាដាំង ចំពោះព្រះនាង មានកម្លាំងធំសម្បើមក្រៃពេក  លុះបុរសបានមកនៅជាមួយនឹងព្រះនាងតែម្នាក់ឯងម៉ង់ៗដូច្នេះ អ្នកពុំអាចរករឿងជជែក ជាមួយនឹងព្រះនាងឱ្យបានយូរឡើយ  អ្នកគ្រាន់តែបង្ហើបវាចាដ៏ខ្លី  ដែលពេញទៅដោយចិត្តស្នេហាទៅកាន់ព្រះនាងម្ចាស់ក្សត្រីថា : “នៃព្រះនាងជាទីស្នេហាដ៏ស្មើថ្លើមប្រមាត់របស់ទូលព្រះបង្គំ  សូមព្រះបាទបានសេចក្តីសុខពិតប្រាកដ  ពិតមែនតែកម្លាំងនៃសេចក្តីស្នេហា  ដែលកើតមានឡើងមកលើរូបទូលបង្គំ ដោយសារតែរូបសម្បត្តិសម្ផស្សនិងសម្រស់  ព្រះនាងនោះមានទំហំធំធេងយ៉ាងណាក៏មិនអាចធ្វើឱ្យទូលបង្គំរំលោភលើព្រំដែនដែលត្រូវគោរព  ចំពោះព្រះនាងបានឡើយ  ។ តែបើសិនជាទូលបង្គំបានរំលោភលើខណ្ឌសីមានេះវិញ គឺមិនមែនមានបំណងនឹង ប្រមាថឬមើលងាយព្រះនាងដែរ  គឺគ្រាន់តែរាំងរាកុំឱ្យគូប្រណាំងអយុត្តិធម៌យកព្រះនាងធ្វើជាភរិយាបាន  ដែលជាអំពើផ្ទុយនឹងព្រះរាជសន្យានៃព្រះបាទស៊ុលតង់ បិតាព្រះនាងតែប៉ុណ្ណោះទេ ។

ព្រះអង្គម្ចាស់ក្សត្រី  ដែលពុំយល់នូវហេតុការណ៍ដូច្នោះសោះក៏ឥតបាននឹកឃើញដល់រឿងដែលអាឡាដាំងនិយាយប្រាប់ប៉ុន្មានឡើយ ។ ព្រះនាងពុំអាចរករឿងអ្វីឆ្លើយតបវិញបានទេ  ។ សេចក្តីភ័យបារម្ភ

នឹងសេចក្តីងឿងឆ្ងល់ ដែលព្រះនាងទើបតែនឹងបានជួបប្រទះក្នុងពេលនេះ បានប្រានទម្លាក់ព្រះនាងឱ្យឋិតនៅក្នុងស្ថានភាពដូច្នេះដែលអាឡាដាំងទាល់គំនិត ពុំដឹងគិតរឿងអ្វីធ្វើឱ្យព្រះនាងមានព្រះសវនីយ៍តបតមកខ្លួនវិញបាន ។ ប៉ុន្តែទោះដូចម្តេចក៏ដោយ អាឡាដាំងឥតនៅស្ងៀមឡើយ បុរសថយទៅដោះសម្លៀកបំពាក់ចេញរួចចូលទៅគេងលើកន្លែង ដែលកូនលោកនាយករដ្ឋមន្ត្រី គេងពីមុនតែបែរខ្នងទៅឱ្យព្រះនាង ។ មិនគ្រាន់តែបែរខ្នងប៉ុណ្ណោះទេ អ្នកថែមទាំងយកកាំបិតស្នៀតមួយ ដាក់ឃាំងចំកណ្តាលទៀតផង ជាសញ្ញាថាបើសិនជាអ្នកប្រព្រឹត្តរំលោភធ្វើឱ្យខូចព្រហ្មចារីរបស់ព្រះនាង អ្នកនឹងត្រូវមានទោស ។

អាឡាដាំងសប្បាយចិត្ត ដោយបានបង្អត់គូប្រណាំងរបស់អ្នកមិនឱ្យក្រេបនូវសុភមង្គលរបស់គេបាននៅយប់នោះ ក៏គេងស្ងើរតែពុំលក់សោះ ។ ឯព្រះនាងបាឌ្រូលប៊ូឌូរ ក៏ឥតផ្ទំលក់មួយព្រិមដែរ។ តាំងពីព្រះនាងទ្រង់ប្រសូតមកព្រះនាងពុំដែលបានជួបប្រទះ នឹងរឿងហេតុដូច្នេះឡើយ ដែលបណ្តាលឱ្យព្រះនាងផ្ទំបើកព្រះនេត្រទើសភ្លឺ។ ប៉ុន្តែបើសិនជាគេយកទុក្ខរបស់បុត្រីព្រះបាទស៊ុលតង់ទៅប្រៀបនឹងទុក្ខរបស់កូនលោកនាយករដ្ឋមន្ត្រីរីងរឹតលែងគេងលក់សោះឡើយ។ អ្នកមានសេចក្តីអន្ទះអន្ទែង តប់ប្រមល់ទល់ប្រធោជាងព្រះនាងជប់សួនទៅទៀត ។



លុះស្អែកឡើង អាឡាដាំងមិនបាច់យកដៃដុសចង្កៀងហៅអារក្សទៀតទេ បិសាចដ៏ធំស្គមស្លែនោះបានមកដល់ត្រឹមត្រូវតាមពេល ដែលអាឡាដាំងផ្តាំពីល្ងាចឥតខ្វះបន្តិចគឺមកដល់ដំណាលគ្នានឹងពេលដែលអាឡាដាំងស្លៀកពាក់ខោអាវរួច។ មកដល់ភ្លាមអារក្សនោះក៏ពោលទៅកាន់អាឡាដាំងថា : "តើលោកមានការអ្វីនឹងប្រើខ្ញុំ?" ។

– ចូរឯង (អាឡាដាំងបង្គាប់) ទៅលើកកូនលោកនាយករដ្ឋមន្ត្រីដែលឯងបានលើកយកទៅទុកនោះ មកដាក់លើគ្រែនេះ រួចយកទាំងគ្រែទាំងមនុស្សទាំងអស់នេះ ទៅដាក់ក្នុងព្រះបរមរាជវាំងព្រះបាទស៊ុលតង់ ត្រង់កន្លែងដែលឯងបានលើកយកមកពីមុន។ អារក្សក៏ចូលទៅយកកូនលោកនាយករដ្ឋមន្ត្រី ដែលឈរត្រង់ជានិច្ចនៅក្នុងបន្ទប់តូច ដូចជាទាហានឈរយាម ។ កាលដែលកូនលោករដ្ឋមន្ត្រីមកដល់កូនមុស្តាហ្វា ក៏លូកដៃយកកូនកាំបិតស្នៀតចេញពីលើគ្រែ អារក្សផ្តេកបុរសកម្សត់ទៅលើគ្រែជិតព្រះនាង រួចលើកទូលគ្រែនោះវឹងយកទៅដាក់ក្នុងបន្ទប់ដដែល នៅក្នុងព្រះរាជដំណាក់ព្រះនាងវិញ ។

តែសូមជ្រាបថា ក្នុងករណីនេះក៏ដោយ ព្រះអង្គម្ចាស់ក្សត្រីនិងបុត្រលោកនាយករដ្ឋមន្ត្រី ឥតបានឃើញដូចម្តេចទេ ។ រូបរាងដ៏ស្គមស្លែរបស់វាអាចធ្វើឱ្យជនទាំងពីរនេះស្លាប់ដោយសេចក្តីខ្លាចពុំខានបើសិនជាបានឃើញរូបអារក្ស ។ សូម្បីតែសម្តីដែលអាឡាដាំង នឹងអារក្សនិយាយគ្នាក៏ជនទាំងពីរនេះឥតស្តាប់ឮឡើយ អ្នកគ្រាន់តែដឹង

ថា គ្រែនោះញ័រហើយហោះពីកន្លែងមួយទៅកន្លែងមួយ ។ ហេតុនេះហើយបាន ជាព្រះអង្គម្ចាស់ក្សត្រីនិងបុត្រលោកនាយករដ្ឋមន្ត្រីមិនសូវតក់ស្លុតប៉ុន្មាន ។

អារក្សទើបតែនឹងដាក់គ្រែលើកន្លែងដើមរួចភ្លាម ព្រះបាទស៊ុលតង់ទ្រង់យាងចូលទៅក្នុងបន្ទប់នោះដែរ ព្រោះព្រះអង្គទ្រង់ចង់ជ្រាបថា តើពីយប់មិញ ព្រះរាជបុត្រីព្រះអង្គឥតមានកើតហេតុអ្វីប្លែកទៀតឬទេ ។ បុត្រលោកនាយករដ្ឋមន្ត្រី ដែលរងាត្រូវខ្យល់អស់កម្លាំងរសេះរសោះរោយដៃរោយជើង ព្រោះឈរមួយយប់ទល់ភ្លឺព្រឹកឡើង ហើយក៏ពុំទាន់បានស្លៀកពាក់ គ្រប់ដណ្ដប់កាយទៀត លុះឮសូរទ្វារបើកភ្លាម ក៏ក្រោកឡើងស្ទុះទៅយកអាវបំពង់វែងដែលសម្រាប់ពាក់គេង វេលាយប់ មកពាក់មួយរំពេច ។

ព្រះបាទស៊ុលតង់ ក៏យាងចូលទៅជិតព្រះរាជបុត្រីឱបថើបព្រះភក្ត្រតាមទម្លាប់រួច ក៏សួរសុខទុក្ខបុត្រីអំពីយប់ដែលទើបនឹងកន្លងមកនេះ តើមានហេតុអ្វីទេ ។ លុះឃើញព្រះភក្ត្ររាជបុត្រីកាលណា ព្រះបាទស៊ុលតង់ ក៏ស្រឡាំងកាំង ព្រោះឃើញទឹកមុខបុត្រីនៅស្មើធម្មតាគ្មានកន្លែងណាដែលជាសញ្ញាឱ្យដឹងថា ព្រះនាងបានរួមដំណេកជាមួយគ្នាឡើយ ។ ព្រះនាងគ្រាន់តែបញ្ចោញទឹកព្រះភក្ត្រព្រួយជាសញ្ញាឱ្យដឹងថា ព្រះនាងមានទុក្ខជាទម្ងន់ ។ ព្រះបាទស៊ុលតង់ខំមានព្រះរាជឱង្ការទៅកាន់បុត្រីព្រះអង្គណាស់ ប៉ុន្តែឥតអំពើទេ ព្រះនាង



ឥតមានព្រះសវនីយ៍តបឡើយ ។ ព្រះអង្គក៏ទ្រង់យាងចេញពីក្នុងបន្ទប់នោះ ដោយទ្រង់នឹកស្មានមានសេចក្ដីខ្មាសអៀនដែលជាធម្មតារបស់ស្រី ដែលទើបនឹងរៀបការរួច ។ ប៉ុន្តែអាការៈព្រះនាងនេះពុំអាចធ្វើឱ្យព្រះបាទស៊ុលតង់គ្មានសេចក្ដីសង្ស័យឡើយ ។ ដូច្នេះព្រះអង្គក៏យាងសំដៅទៅដំណាក់ព្រះមហាក្សត្រីយានីភ្លាមមានព្រះរាជឱង្ការរ៉ាយរ៉ាប់សព្វគ្រប់ ទូលព្រះរាជិនីអំពីដំណើរការដែល ព្រះអង្គបានទតព្រះរាជបុត្រី និងអំពីបដិសណ្ឋារកិច្ចរបស់ព្រះនាងចំពោះព្រះអង្គ ។ ព្រះមហាក្សត្រយានី ក៏ទ្រង់មានព្រះសវនីយ៍ឆ្លើយតបវិញថា : “បពិត្រ ព្រះស្វាមី ! សូមព្រះអង្គកុំទ្រង់ឆ្ងល់ឱ្យសោះ ជាធម្មតារបស់ស្រីដែលរៀបអាពាហ៍ពិពាហ៍រួចតែងមានអាការៈដូច្នេះនៅវេលាថ្ងៃបន្ទាប់ពី ថ្ងៃផ្សំដំណេកមក ។ តែពីរបីថ្ងៃទៀត បុត្រីយើងមុខជានឹងធ្វើបដិសណ្ឋាកិច្ចទទួល ព្រះអង្គជាព្រះបិតាដូចជាធម្មតាទៅហើយ ។ ដូច្នេះចាំខ្ញុំម្ចាស់ទៅមើលម្ដង បើសិនជាវានៅ តែមានអាការៈដដែលទេនោះ ចាំថាខ្ញុំម្ចាស់យល់ខុសចុះ” ។

លុះព្រះមហាក្សត្រីយានី ទ្រង់ព្រះពស្ត្ររួចក៏យាងតម្រង់ទៅដំណាក់ព្រះអង្គម្ចាស់កូន ដែលកំពុងផ្ទំនៅឡើយព្រះអង្គទ្រង់ខិតចូលទៅជិតគ្រែ ឱនត្រកងព្រះរាជបុត្រី ដើម្បីជាទិវាសួស្ដី ។ ប៉ុន្តែព្រះរាជជននីនាថ ទ្រង់មានសេចក្ដីងឿងឆ្ងល់ជាខ្លាំង គឺមិនត្រឹមតែងឿងឆ្ងល់នឹងព្រះនាងមិនមានព្រះសវនីយ៍នោះទេ គឺងឿងឆ្ងល់ដោយបានឃើញ

ព្រះនាងមានទឹកព្រះភក្ត្រស្រពោនស្រពន់សញ្ជាប់សញ្ជឹងរវើរវាយ ជាហេតុនាំឱ្យព្រះអង្គ ទ្រង់ល្ហែងយល់បានថា ប្រាកដជាមានកើតរឿងហេតុអ្វី ដល់ព្រះរាជបុត្រីអញទៀតហើយ ដែលព្រះរាជបុត្រីឥតទ្រង់យល់បន្តិចសោះឡើយ ។ ដូច្នេះព្រះមហាក្សត្រិយានីទ្រង់មានព្រះសវនីយ៍សួរឡើងថា : "នែកូនស្រី ! ចុះកូនទឹកឃើញដូចម្តេចបានជាធ្វើសោះអង្កើយមករកម្តាយដូច្នេះ តើចំពោះម្ចាស់ម៉ែបង្កើតកូនត្រូវធ្វើឫកពាដូច្នេះឬ? ហើយឯងនឹកស្មានថា អញពុំធ្លាប់ដឹងនូវហេតុផ្សេងៗ ដែលកើតមានឡើងក្នុងពេលដូច្នេះឬ? ម្តាយជឿច្បាស់ថា កូនឯងមិនមានហេតុដូច្នេះទេ គឺប្រាកដជាមានកើតហេតុដទៃទៀតហើយ ។ ហេតុនេះចូរឯងនិយាយប្រាប់ម្តាយឱ្យត្រង់មក កុំទុកឱ្យម្តាយព្រួយចិត្ត តែនឹងឯងទៀត" ។

ព្រះនាងបាឡូលប៊ូខូរក៏ដកដង្ហើមធំ រួចមានព្រះសវនីយ៍យ៉ាងខ្លាំងថា : "ឱព្រះមាតាជាទីស្នេហារបស់កូនអើយ ! សូមព្រះមាតាទ្រង់មេត្តា ព្រះរាជទានអភ័យទោសដល់ខ្ញុំម្ចាស់ជាកូនផង បើសិនជាកូនមានការលើសលស់ខុសឆ្គងពុំសមរម្យត្រង់កន្លែងណាដ្បិតខួរក្បាលកូនកំពុងវិលវល់ខ្វល់ខ្វាយជាប់ជំពាក់ចាក់ស្រេះ គិតពុំលេច ពុំយល់ពុំដល់ នឹងការចម្លែកអស្ចារ្យមួយដែលកើតមានមកពីយប់មិញ" ។ ឥឡូវនេះ កូនពុំទាន់បាត់ឆ្ងល់នឹងបាត់ភ័យស្រួលបួលផង កូនស្ទើរតែពុំទាន់ដឹងថា ខ្លួនកូននៅត្រង់កន្លែងណាផងឡើយ ។ បន្ទាប់មក ទើប



ព្រះនាងមានព្រះសវនីយ៍ប្រាប់ព្រះមាតាយ៉ាងច្បាស់លាស់ អំពីការនោះ គឺថាក្រោយពេល ដែលស្វាមីព្រះនាង និងព្រះនាងចូលភ្លាម ស្រាប់តែគ្រែនោះហោះ ចេញពីក្នុងបន្ទប់ ។ មួយសន្ទុះក៏គ្រែនោះទៅនៅក្នុងបន្ទប់មួយយ៉ាងកខ្វក់ហើយងងឹតផង ។ ទៅដល់កន្លែងនោះព្រះនាងនៅផ្ទៃតែម្នាក់ឯង បាត់ស្វាមីពុំដឹងនៅឯណា ។ បន្ទាប់ពីនោះមកព្រះនាងស្រាប់តែឃើញបុរសម្នាក់ ចូលមកនិយាយជាមួយនឹងព្រះនាង ប៉ុន្តែដោយមានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ព្រះនាងពុំអាចស្តាប់ថាដូចម្តេចឡើយ ។

បុរសនោះចូលមកគេងលើគ្រែជំនួសប្តីព្រះនាង ក្រោយដែលបានយកកាំបិតស្នៀតមួយ ដាក់ឃាំងចំកណ្តាល ។ លុះគេយកប្តីព្រះនាងមកដាក់នៅលើគ្រែវិញ គ្រែក៏អណ្តែតមកកន្លែងនេះវិញដដែល ។ ព្រះនាងមានព្រះសវនីយ៍បន្ថែមទៀតថា : "ការនេះមិនទាន់ទាំងកន្លងផុតទៅផង ស្រាប់តែព្រះបិតាយាងចូលមកដល់ពេលនោះ កូនកំពុងតែខ្វល់ក្នុងចិត្តជាក្រៃលែង រកតែកម្លាំងឆ្លើយតបទៅនឹងព្រះបិតាវិញសូម្បីតែមួយម៉ាត់ក៏ពុំបានឡើយ ហើយកូនពុំមែនមិនដឹងទេថា ព្រះបិតាពិតជាទ្រង់ខ្ញាល់នឹងកូនហើយ ។ ប៉ុន្តែកូនសង្ឃឹមថា ព្រះបិតាមុខជាទ្រង់លស់លាត្រាប្រណីទៅកូនពុំខាន កាលបើព្រះអង្គទ្រង់ជ្រាបនូវទុក្ខរបស់កូន ដែលកំពុងគ្របសង្កត់លើទ្រូងកូនប៉ុនភ្នំនេះ ។

ព្រះមហាក្សត្រិយានីស៊ុលតាន ជាមាតាទ្រង់ព្រះសណ្តាប់យ៉ាង

សព្វគ្រប់នូវព្រះសវនីយ៍ព្រះរាជបុត្រី ប៉ុន្តែព្រះអង្គឥតទ្រង់ជឿឡើយ ទើបមានព្រះសវនីយ៍តបទៅវិញថា : "កូនស្រីម្ដាយ ! ដែលឯងមិនបាននិយាយការនេះទូលបិតានោះៗ ជាការប្រសើរណាស់ ។ ដូច្នេះចូរកូនឯងកុំនិយាយប្រាប់អ្នកឯណាដទៃទៀតឱ្យសោះ ។ គេនឹងថាកូនឯងវិកលចរិតពុំខាន បើសិនជាគេឮកូននិយាយដូច្នេះទៀត ។ - ទេ អ្នកម្ដាយកូនសូមជម្រាបថា ដែលកូនពោលនេះ ក៏កូនមានសុភវិនិច្ឆ័យសព្វគ្រប់ក្នុងខ្លួន បើពុំនោះសោតសូមអ្នកម្ដាយទៅសួរប្ដីខ្ញុំមើលគេនឹងពោលដូចតែខ្ញុំនេះដែរ ។- អើ ! ម្ដាយមុខជាទៅសួរប្ដីឯងទៀតហើយ, ប៉ុន្តែបើទុកជាប្ដីឯងនិយាយដូចឯងដែរនោះ, ក៏ម្ដាយនៅតែពុំជឿទៀតដែរ ។ ហេតុនេះ ចូរកូនឯងក្រោកឡើង ហើយឈប់លែងនឹកនាដល់រឿងអ្វីទៀតទាំងអស់ ។ បើពុំនោះទេ កូនឯងប្រាកដជាធ្វើឱ្យរំខានដល់មង្គលនេះពុំខានឡើយ ដែលគេត្រូវធ្វើអស់ពេលជាច្រើនថ្ងៃទៀតនៅក្នុងព្រះបរមរាជវាំងនេះនឹងនៅក្នុងព្រះរាជអាណាចក្រទាំងមូល ។ កូនឯងមិនឮសម្លេងហ្វង់ហ្វារខ្លុយ និងស្គរភេរីទេឬ? សូរស័ព្ទនេះហើយដែលធ្វើឱ្យកូនឯង កើតមានសេចក្ដីសប្បាយរីករាយសោមនស្សបំភ្លេចនូវការរវើរវាយផ្សេងៗ ដែលកូនឯងទើបតែនិយាយប្រាប់ម្ដាយអម្បាញ់មិញនេះ ។ ក្នុងពេលមួយរំពេចនោះព្រះបាទស៊ុលតាន ក៏មានព្រះសវនីយ៍ ហៅស្រីស្នំក្រមការរបស់ព្រះរាជបុត្រីឱ្យចូលមកគាល់ព្រះនាង ។ ក្រោយពេលដែលបានឃើញព្រះរាជបុត្រីតើនពីផ្ទំ និងលុប



លាងសម្អាតព្រះកាយរួច ព្រះរាជជននីស្ដេចយាងតម្រង់ទៅដំណាក់ព្រះបាទស៊ុលតង់រួចទូលថាកូន យើងមិនសូវស្រួលក្នុងខួរក្បាលមែន ប៉ុន្តែគ្មានជាការអ្វីទេ ។ តពីនោះ មកព្រះមហាក្សត្រិយានី ក៏ទ្រង់បង្គាប់ឱ្យគេទៅហៅកូនលោកនាយករដ្ឋមន្ត្រីមក ដើម្បីនឹងសាកសួររឿង ។ ហេតុតែចង់បានមុខមាត់ធ្វើស្ពានមេត្រីជាមួយនឹង ព្រះបាទស៊ុលតង់ ក៏ឥតទូលរឿងពិតដល់ព្រះអង្គឡើយ ។ ព្រះមហាក្សត្រិយានីក៏ទ្រង់ត្រាស់សួរថា : "នែកូនប្រុសម្ដាយ ! ចូរឯងនិយាយប្រាប់ម្ចាស់ម៉ែមើល តើឯងមានកើតហេតុដូចប្រពន្ធឯងទេ? អ្នកម្ដាយ ! តើអ្នកម្ដាយចង់សួរកូនពីរឿងអ្វីហ្នឹង ។ ណ្ហើយប៉ុណ្ណឹងបានហើយ ម្ដាយលែងសួរកូនឯងទៀតហើយ កូនឯងមានអាការៈខុសពីប្រពន្ធឯងទេ" ។

គេលេងភ្លេងសប្បាយ គគ្រឹកគគ្រេងរំពងអឹងកងរងៀងរាល់ថ្ងៃក្នុងព្រះបរមរាជវាំង ។ ព្រះមហាក្សត្រយានីដែលពុំដែលហ៊ានឃ្លាតចេញឆ្ងាយពីបុត្រីសោះនោះ ក៏ពុំភ្លេចនឹងធ្វើឱ្យព្រះនាងសប្បាយដោយណែនាំព្រះនាងឱ្យទតទស្សនីយភាពផ្សេងៗ ដែលគេកំពុងលេង ។ ប៉ុន្តែដោយក្បាលព្រះបាទ នៅកង្វល់មហិមានឹងព្រឹត្តិការណ៍ ដែលកើតមានឡើងពីយប់មិញគេសង្កេតឃើញព្រះបាទឥតផ្លាស់ទឹកព្រះភក្ត្រឡើយ ។ បុត្រលោកនាយករដ្ឋមន្ត្រី ក៏មិនមែនឥតកើតទុក្ខ ពីព្រោះតែរឿងយប់មិញនោះទេ ប៉ុន្តែសេចក្ដីលោភខ្លាំងពេក បានខំលាក់រឿងនេះធ្វើហាក់ដូចជាពុំដឹងសោះ ។ បើគ្រាន់តែក្រឡេកមើលមួយភ្លែត

អ្នកផងក៏កើតសង្ស័យឡើងថា ប្រុសកំលោះនេះ កំពុងសប្បាយចិត្តណាស់ ។

និទានពីអាឡាដាំង កាលបើបានដឹងពិតប្រាកដនូវរឿងហេតុដែលមានឡើងនៅក្នុងព្រះបរមរាជវាំង ក៏លែងសង្ស័យថាគូសង្សារថ្មីនេះបានរួមដំណេកជាមួយគ្នាហើយ ។ ការណ៍នេះ គឺមកពីយប់មុនមានកើតឧបត្តិហេតុដ៏អស្ចារ្យដល់គូសង្សារទាំងពីរ ។ តែទោះជាយ៉ាងណា ក៏ដោយក៏អាឡាដាំង មិនព្រមទុកឱ្យគូសង្សារទាំងពីរនេះបានឡើងថានសួគ៌ជាមួយគ្នាបានទេ ។ ដូច្នោះ លុះយប់យន់បន្តិចអាឡាដាំងក៏ទៅយកចង្កៀងមកគោះហៅអារក្សៗ ក៏ចូលមកអភិវន្ទនាការដូចមុនៗ ។ អាឡាដាំងក៏បង្គាប់ឡើងថា : "បុត្រលោកនាយករដ្ឋមន្ត្រី និងព្រះនាងបាឌ្រូលប៊ូឌួរ ត្រូវរួមដំណេកជាមួយគ្នាទៀតល្ងាចនេះ ដូច្នេះនៅពេលដែលគូសង្សារនេះចូលនិទ្រា ចូរអ្នកលើកគ្រែនោះយកមកឱ្យខ្ញុំដូចពីម្សិលមិញទៀត" ។

អារក្សក៏ធ្វើតាមបង្គាប់អាឡាដាំង ឥតមានធ្វេសប្រហែសឡើយ ។ កូនលោកនាយករដ្ឋមន្ត្រីត្រូវគេងនៅកន្លែងដ៏លំបាកដូចពីយប់មុនដដែល ព្រះអង្គម្ចាស់ក្សត្រីត្រូវគេងជាមួយអាឡាដាំងទៀតដោយមានកាំបិតស្នៀតមុខសស្ងាចឃាំងនៅចន្លោះកណ្ដាល ។ លុះស្អែកឡើង តាមបង្គាប់អាឡាដាំង អារក្សក៏យកកូនលោកនាយករដ្ឋមន្ត្រីមកដាក់ជាមួយភរិយាវិញ រួចក៏លើកទូលគ្រែនោះ យកទៅដាក់ក្នុងប្រាសាទ ត្រង់បន្ទប់ដដែល ។



ព្រះអង្គស៊ុលតង់ ចាប់តាំងពីពេលដែលបានយាងទៅសួរព្រះរាជបុត្រីមកកាលណា ព្រះអង្គទ្រង់បារម្ភជានិច្ចដោយទ្រង់ចង់ជ្រាបថាតើយប់ទីពីរព្រះបាទមានអាការៈដូចម្ដេច ឬមួយក៏នៅតែដដែលដូចពីរាត្រីមុននោះទេ។ ទើបស្អែកឡើង ព្រះអង្គទ្រង់យាងពីព្រលឹមទៅដំណាក់បុត្រី ដើម្បីនឹងបានជ្រាបការណ៍នេះច្បាស់ ។ កូននាយករដ្ឋមន្ត្រីដែលកំពុងតែមានសេចក្ដីខ្មាសអៀននិងឈឺចាប់ក្នុងចិត្តក្រៃលែងនឹងអំពើអលទ្ធផលលើសពីយប់ទីមួយទៀតនោះ។ កាលបើឮសូរព្រះបាទស៊ុលតង់យាងចូលមក ក៏ស្ទុះម្នីម្នាទៅចាប់យកអាវផាយមកពាក់ភ្លាម ។

ព្រះបាទស៊ុលតង់ យាងចូលទៅដល់គ្រែព្រះរាជបុត្រីសំដែងទិវាសួស្ដីតាមធម្មតា រួចក៏មានព្រះបន្ទូលឡើងថា : "ម៉េចទៅកូនស្រីប៉ា ! តើព្រឹកនេះ ឯងមានកើតហេតុអ្វីដូចពីម្សិលមិញទៀតទេ? ចូរឯង និយាយប្រាប់ប៉ាមើល តើពីយប់មិញឯងទទួលទានដំណេកបានស្រួលបួលទេ?" ប៉ុន្តែព្រះរាជបុត្រីទ្រង់នៅស្ងៀមដដែល ឥតមានព្រះសវនីយ៍ តបទៅនឹងព្រះបិតាឡើយ ។

ព្រះបាទស៊ុលតង់ទតឃើញកូននៅធ្ងឹងថ្លៃ លើសពីថ្ងៃមុនទៅទៀត, ក៏ទ្រង់នឹកក្នុងព្រះទ័យថា បុត្រីអញប្រាកដជាមានកើតរឿងហេតុអ្វីធំហើយ ។ ខ្វាល់នឹងកូន ដែលលាក់រឿងសម្ងាត់មិនព្រមប្រាប់បិតា, ព្រះអង្គក៏តម្លោះកាំបិតកែកាន់នៅដៃ រួចមានព្រះបន្ទូលថា :

"កូនស្រីប៉ា ! ឬមួយកូនព្រមនិយាយប្រាប់ឪពុក នូវការអាថិកំបាំង នោះ, ឬមួយសុខចិត្តឱ្យឪពុកកាត់ក្បាលឯងចោល ក្នុងពេលឥឡូវ នេះ? " ។

ព្រះនាងប៉ាឡ្រូលប៊ូឌូរ ទ្រង់ភ័យញ័រនឹងព្រះបន្ទូលដ៏ខ្លាំងៗ នៃ ព្រះបាទស៊ុលតង់, ហើយនឹងមុខកាំបិតស្នៀតដ៏សស្វាច ដែលទ្រង់កាន់ នៅព្រះហស្ត, ទើបមានព្រះសវនីយ៍ទាំងបង្ហូរអស្សុជលនេត្រឡើងថា: "ព្រះរាជបិតាជាទីស្នេហារបស់កូន! កូនសូមទោសព្រះបិតាថ្លៃវិសេស, បើសិន ជាកូនមានចេតនាប្រមាថមើលងាយព្រះបិតាមែននោះ ។ កូន សង្ឃឹមថា ព្រះបិតានឹងឈប់ខ្ញាល់ហើយបែរមកជាទ្រង់អាណិតមេត្តា កូនស្ទើរខ្លោចព្រះទ័យទៅវិញ, កាលបើកូននិយាយទូលរឿងពិតរបស់ កូនដែលបានភប់ប្រទះក្នុងយប់មិញ និងយប់ដែលកន្លងផុតមកហើយ ថ្វាយព្រះបិតាជ្រាប "។

ក្រោយដែលព្រះនាង បានរៀបរាប់អំពីបុព្វហេតុត្រូវៗ ទូល ដូច្នោះ, ព្រះបាទស៊ុលតង់ ក៏ទ្រង់នៅស្ងៀមបន្តិចពុំសូវខ្ញាល់ពេក ។ ឯព្រះនាង ក៏មានព្រះសវនីយ៍យ៉ាងភក្តីភាព ទូលព្រះបិតាអំពីរឿង ហេតុដែលកើតមានឡើងទាំងអម្បាលម៉ាន ក្នុងរាត្រីអពមង្គលទាំង ពីររឿងនោះ បានធ្វើឱ្យព្រះបាទស៊ុលតង់ រំភើបដល់សរសៃហទ័យ កើតព្រះទ័យមេត្តាករុណាអាសូរព្រះរាជបុត្រីជាក្រៃលែង។ ព្រះអង្គ ពោលបន្ថែមទៀតថា : "បើសិនព្រះបិតានៅមានសង្ស័យត្រង់កន្លែង



ណាក្នុងរឿងនេះ សូមទ្រង់យាងទៅសួរស្វាមីកូនទៀតចុះ។ កូនជឿ ជាក់ថា គេនឹងទូលរឿងពិតនេះ ដល់ព្រះបិតា ដូចជាកូនបានទូលរួច មកហើយដែរ" ។

ព្រះបាទស៊ុលតង់ ឥតមានសង្ស័យអ្វីទៀតឡើយ ព្រះអង្គទ្រង់ យល់ច្បាស់ នូវហេតុដ៏អស្ចារ្យ ដែលពុំដែលមាន ហើយកើតមានឡើង ដល់ព្រះរាជបុត្រី ។ ដូច្នេះ ព្រះអង្គក៏មានព្រះបន្ទូលទៅកាន់ព្រះរាជ បុត្រីថា : "កូនស្រីព្រះបិតា ! កូនឯងយល់ខុសសោះ ដែលពុំព្រម ប្រាប់រឿងនេះ ដល់ព្រះបិតា តាំងពីពេលម្សិលមិញមក, បិតាក៏ដូចជា កូនឯងដែរចង់ជ្រាបហេតុនេះណាស់ ។ មួយចំណែកទៀត ត្រូវកូនឯង ដឹងថា បិតាដែលខំរៀបចំកូនឯងឱ្យមានគូស្រករនេះ គឺមិនមែនមាន ប្រាថ្នាចង់ឱ្យតែកូនឯង កើតទុក្ខលំបាកវេទនាខ្លួនទេ គឺប្រាថ្នាចង់ឱ្យ តែកូនឯង បានសុខបានសប្បាយនិងឱ្យបានក្រេបនូវសុភមង្គលគ្រប់ ជំពូកសមរម្យទៅតាមឋានៈកូនឯងដែលជាបុត្រីព្រះមហាក្សត្រសោយ រាជ្យនឹងអាចឱ្យកូនឯងសង្ឃឹមថានឹងបានរស់នៅជាសុខសាន្តជាមួយ នឹងព្រះស្វាមីដែលបិតាបានរើសឱ្យ ។ ដូច្នេះកូនឯងលែងនឹកនាដល់ រឿងអពមង្គលឧបទ្រពចង្រៃដែលកូន ទើបនឹងនិយាយប្រាប់បិតា អម្បាញ់មិញទៀតឱ្យសោះ ។ បិតានឹង ទៅគិតគូរសម្រេចរឿងនេះ ឱ្យទាល់តែបានស្រួលដល់កូនឯង" ។

លុះព្រះអង្គយាងចូលទៅដល់ព្រះរាជដំណាក់, ទ្រង់ក៏ចាត់ ព្រះរាជបម្រើឱ្យទៅអញ្ជើញលោកនាយករដ្ឋមន្ត្រីមកភ្លាម រួចព្រះអង្គ

ក៏មានព្រះរាជឱង្ការថា : “លោកនាយក ! តើលោកបានទៅជួបបុត្រលោកហើយឬនៅ ហើយតើបុត្រលោកមាននិយាយរឿងអ្វីជម្រាបលោកខ្លះទេ? កាលបើលោកនាយករដ្ឋមន្ត្រី ទូលតបទៅវិញថា : “ពុំដែលបានជួបទេ. ព្រះបាទស៊ុលតង់ក៏មានព្រះរាជឱង្ការរៀបរាប់សព្វគ្រប់នូវហេតុការណ៍ទាំងឡាយ ដែលព្រះនាងបាទ្រូលប៊ូឌួរ បានទូលជូនលោកនាយករដ្ឋមន្ត្រីស្តាប់ ។ នៅទីបញ្ចប់ព្រះអង្គទ្រង់ បន្ថែមថា : “ខ្ញុំជឿជាក់ណាស់ថា បុត្រីខ្ញុំមិនមែន កុហកខ្ញុំឡើយ ។ ប៉ុន្តែខ្ញុំចង់ដឹងណាស់ដែរថា តើបុត្រលោកមានកើតរឿងហេតុដូច្នោះដែរឬ? ហេតុនេះចូរលោកអញ្ជើញទៅសួរ បុត្រ លោកផងមើល” ។

លោកនាយករដ្ឋមន្ត្រី ក៏អញ្ជើញប្រញាប់ប្រញាល់ទៅជួបកូនៗនិយាយរឿងប្រាប់សព្វគ្រប់ ដូចដែលព្រះមហាក្សត្របានមានព្រះបន្ទូលប្រាប់គាត់រួច ក៏ពោលដាក់កំហិតឱ្យកូនថា ចូរឯងនិយាយប្រាប់ឪពុកឱ្យត្រង់ បើសិនជាការនេះពិតដូច្នេះមែន កុំគប្បីអ្នកពោលកុហកវៀចវេរឱ្យសោះ ។

បុត្រលោកនាយករដ្ឋមន្ត្រី ក៏ឆ្លើយតបនឹងឪពុកវិញថា: “ខ្ញុំមិនពោលកុហកលោកឪពុកធ្វើអ្វីទេ. រឿងដែលព្រះនាងមានបន្ទូលទូលព្រះបាទស៊ុលតង់នោះ គឺពិតដូច្នោះមែន ។ នៅខ្វះបន្តិចតែត្រង់ព្រះនាងឥតបានព្រះសវនីយ៍រាប់រៀបពីរឿងខ្ញុំផងសោះ។ ឯរឿងខ្ញុំមានដូចតទៅនេះ:



ចាប់តាំងពីថ្ងៃរៀបអាពាហ៍ពិពាហ៍រួចមក. ពីរយប់មកហើយដែលខ្ញុំត្រូវរួមដំណេកនោះ ជាយប់ចង្រៃអពមង្គលយ៉ាងក្រៃលែងដែលខ្ញុំពុំអាចរកពាក្យអ្វីឱ្យចំដើម្បីនឹងព័ណ៌នានូវទុក្ខវេទនារបស់ ខ្ញុំឱ្យបានសព្វគ្រប់ជូនលោកឪពុកស្តាប់ឡើយ ។ នេះកូនមិនគិតដល់សេចក្តីញាប់ញ័រតក់ស្លុតដែលគេលើកសែងយកគ្រែកូនកំពុងគេងអស់ពេល៤លើកផង គឺយកពីកន្លែងមួយដោយឥតទាំងបានឃើញថានរណាលើកគ្រែនោះសោះ ហើយតើគេធ្វើដូចម្តេចខ្លះ? ។ សូមលោកឪពុកយកទៅពិចារណាខ្លួនឯងចុះ។ កាលបើខ្ញុំជម្រាបថា អស់ពេលពីររាត្រីហើយដែលខ្ញុំឈរខ្លួនទទេមានតែអាវមួយគត់នៅក្នុងបន្ទប់មួយដ៏ចង្អៀតក្រៃលែងរកតែរើខ្លួនឬធ្វើចលនាអ្វីបន្តិចក៏ពុំបាន ពិតមែនតែទឹកមុខខ្ញុំហាក់ដូចជាគ្មានអ្វីជាឧបសគ្គឡើយ។ ក្រោយពីនោះមក ខ្ញុំពុំចាំពោលឱ្យវែងឆ្ងាយសព្វគ្រប់នូវទុក្ខវាយរងរបស់ខ្ញុំទៀតទេ ។ គឺខ្ញុំពុំដឹងលាក់ធ្វើអ្វីទៀតទេ. ឧបត្ថិហេតុទាំងនោះពុំអាច រាំងរាខ្ញុំមិនឱ្យនឹកដល់ព្រះនាងជាភរិយាខ្ញុំ ដែលខ្ញុំត្រូវតែមានសេចក្តីគោរពនឹងដឹងគុណបានឡើយ ។ ប៉ុន្តែក្នុងពេលនោះ ខ្ញុំសូមជម្រាបលោកឪពុកដោយត្រង់អស់ពីពោះថា ទោះបីខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងសេចក្តីរុងរឿងដ៏អស្ចារ្យដោយសារបានរៀបការជាមួយព្រះរាជបុត្រីម្ចាស់ផែនដីខ្ញុំនោះក៏ដោយ ខ្ញុំក៏ពុំអាចរស់នៅក្នុងឋានៈដូច្នេះតទៅទៀតឡើយ។ គឺខ្ញុំសុខចិត្តស្លាប់ខ្លួនប្រសើរជាជាងរស់ឱ្យ បានយូរជាមួយគ្រួសារដ៏

ខ្ពង់ខ្ពស់នេះ, បើនឹងរស់តែជួបទុក្ខសោកគ្រប់យ៉ាងដូច្នេះ ។ ឯព្រះនាងម្ចាស់ក្សត្រីវិញ ខ្ញុំក៏ឥតសង្ស័យបន្តិចដែរថា ព្រះនាងមុខជាពុំមានមនោសញ្ចេតនាប្លែកពីខ្ញុំឡើយ ។ គឺព្រះនាងមុខជាពេញព្រះហឫទ័យថា ការព្រាត់ប្រាសគ្នាពេលនេះ នឹងធ្វើឱ្យព្រះកាយព្រះនាងក្តី ខ្លួនខ្ញុំក្តី បានសុខសប្បាយស្រួលទៅវិញទេ ។ ដូច្នេះលោកឪពុក ! កូនសូមអង្វរលោកឪពុកឱ្យទៅក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងថា អាពាហ៍ពិពាហ៍រវាងម្ចាស់ក្សត្រីនឹងខ្ញុំសន្មតថាជាមោឃៈពីត្រឹមពេលនេះទៅចុះ ។

លោកនាយករដ្ឋមន្ត្រី ទោះមានសេចក្តីលោភលន់ពន់ប្រមាណចង់បានកូនខ្លួនធ្វើជាព្រះរាជធិតុបតិ[(១)] នៃម្ចាស់ផែនដីយ៉ាងណាក៏ដោយក៏ពេលនេះលោកពុំអាចនឹងនិយាយឱ្យកូនលោកទ្រាំអត់ធ្មត់ នៅរួមដំណេកពីរបីថ្ងៃតទៅទៀតបាន ដើម្បីនឹងចាំមើលតើព្រឹត្តិការណ៍នេះនៅតែមានដូច្នេះទៀតឬអ្វី? ។

លោកក៏អញ្ជើញចេញពីកន្លែងកូន, នាំសេចក្តីទៅក្រាបបង្គំទូលថ្វាយព្រះករុណាថា រឿងនោះពិតដូច្នោះមែន ។ ហេតុដូច្នេះហើយ, បានជាគេឃើញលោកនាយករដ្ឋមន្ត្រី ក្រាបថ្វាយបង្គំព្រះបាទស៊ុលតង់

(១) ពាក្យ ៣ម៉ាត់នេះ គឺ : ធិតុបតិ ជាមាតា សុណិសា ប្រែថា : "កូនប្រសា" ដូចគ្នា, តែធិតុបតិ និងជាមាតា ប្រើបានចំពោះតែកូនប្រសាប្រុស, ឯសុណិសាប្រើបានចំពោះតែកូនប្រសាស្រី ។



ទូលថ្វាយព្រះករុណាថា រឿងនោះពិតដូច្នោះមែន ។ ហេតុដូច្នេះហើយ, បានជាគេឃើញលោកនាយករដ្ឋមន្ត្រី ក្រាបថ្វាយបង្គំព្រះបាទស៊ុលតង់
ទូលសូមព្រះរាជានុញ្ញាតយកកូនលោកចេញពីក្នុងព្រះបរមរាជវាំងភ្លាមដោយឥតបង្អង់ចាំឱ្យព្រះបាទស៊ុលតង់មានបន្ទូលពីរឿងផ្តាច់ស្ពានមេត្រីនេះទាន់ឡើយ ។ លោកពោលសម្អាងថា មិនត្រូវទុកឱ្យព្រះនាងម្ចាស់ក្សត្រីព្រួយបារម្ភព្រះទ័យមកតែអំពីសេចក្តីស្នេហា ចំពោះបុត្រនោះឡើយ ។

លោកនាយករដ្ឋមន្ត្រី ក៏បានទទួលសេចក្តីអនុញ្ញាតពីព្រះរាជាភ្លាម ។ នៅពេលនោះ, ព្រះបាទស៊ុលតង់ ដោយបានទ្រង់ត្រិះរិះរឿងនេះជាមុនស្រេចហើយ ក៏ទ្រង់ចាត់ការចេញព្រះរាជសាសន៍ បង្គាប់ឱ្យឈប់លែងធ្វើបុណ្យសប្បាយក្នុងព្រះបរមរាជវាំង, ទីក្រុង និងនៅតាមនិគមជនបទផ្សេងៗ ក្នុងព្រះរាជាណាចក្រទៀត ។ ក្នុងពេលដ៏ខ្លីនេះការសប្បាយគគ្រឹកគគ្រេងគ្រប់បែបគ្រប់យ៉ាង ក្នុងព្រះរាជាណាចក្រក៏បាត់ស្ងាត់ឈឹងសូន្យអស់ ។

ការកើតវិបល្លាសភ្លាមៗដោយឥតមាននរណាយល់ដល់សោះដូច្នេះ ជាហេតុនាំឱ្យកើតមានយោបល់ផ្សេងៗពីគ្នា ។ គេដណ្តឹងសួរគ្នាពីមួយទៅមួយ តើមានកើតឧបត្តិហេតុអ្វីខុសពេលវេលាដូច្នេះ? ។ ប្រជាជនគ្មានដឹងអ្វីក្រៅអំពីថាបានឃើញលោកនាយករដ្ឋមន្ត្រីអញ្ជើញចេញពីព្រះបរមរាជវាំងជាមួយនឹងកូនលោកដោយមានទឹកមុខក្រៀម

ក្រំរៀងៗខ្លួន ។ មានតែអាឡាដាំងមួយទេ ដែលដឹងការអាថ៌កំបាំងនេះ ហើយដែលកំពុងសប្បាយតែម្នាក់ឯង ដោយបានទទួលលទ្ធផលក្នុងការប្រើចង្កៀងទិព្វ ។ ដូច្នេះ, អាឡាដាំង កាលបើបានដឹងដំណឹងយ៉ាងច្បាស់ថា គូប្រណាំងរបស់ខ្លួនបានខ្ចាត់ចេញពីព្រះបរមរាជវាំងហើយ ទាំងរឿងអាពាហ៍ពិពាហ៍ជាមួយម្ចាស់ក្សត្រី ក៏ត្រូវដាច់ចំណងមេត្រីត្រឹមនេះ ក៏ឈប់លែងត្រដុសចង្កៀង ឬលែងត្រូវការហៅអារក្សមកទៀត ប្រយោជន៍កុំឱ្យគូប្រណាំងខ្លួន ជ្រាបនូវរឿងនេះ ។ ប៉ុន្តែការដែលពិសេសនោះគឺថាព្រះបាទស៊ុលតង់ ក្តីលោកនាយករដ្ឋមន្ត្រីក្តី គ្មាននឹកឃើញដល់អាឡាដាំងនិងសេចក្តីស្នើរបស់ម្តាយបុរសនេះសោះ ដែលជាអ្នកបង្កើតហេតុនាំឱ្យអាពាហ៍ពិពាហ៍នៃព្រះនាងម្ចាស់ក្សត្រីត្រូវរលាយទៅវិញ ។ នៅពេលនោះ អាឡាដាំងកំពុងអង្គុយរាប់ថ្ងៃខែយ៉ាងផ្ចិតផ្ចង់ជាទីបំផុតគឺបីខែ ដែលព្រះបាទស៊ុល-តង់បានសន្យាថា នឹងរៀបអភិសេកព្រះរាជបុត្រីបាឌ្រូលប៊ូឌួរជាមួយនឹងខ្លួន។ លុះរាប់ទៅឃើញនៅថ្ងៃខានស្អែក, អាឡាដាំងក៏គ្មានបង្អង់ប្រាប់ម្តាយឱ្យអញ្ជើញទៅវាំង ដើម្បីទូលរំលឹកព្រះបាទស៊ុលតង់ អំពីព្រះរាជឱង្ការក្នុងថ្ងៃមុន ។

ម្តាយអាឡាដាំង ក៏អញ្ជើញទៅព្រះបរមរាជវាំង ដូចដែលកូនបានប្រាប់មែន, គាត់ទៅឈរនៅមុខទ្វារចូលទៅព្រះរាជរោងជំនុំដូចពីពេលមុនទៀត ។ ព្រះបាទស៊ុលតង់ក៏ឆ្មៀងព្រះនេត្រទតឃើញភ្លាម,



ទ្រង់ក៏ស្គាល់និងនឹកឃើញ នូវសេចក្តីស្នើរបស់ម្តាយអាឡាដាំង និងពេលវេលា ដែលព្រះអង្គបានកំណត់ ។ នៅពេលនោះ, លោកនាយករដ្ឋមន្ត្រីក៏ចូលយកសេចក្តីរាយការណ៍សម្រាប់ជំនុំទៅថ្វាយព្រះអង្គៗក៏មានព្រះបន្ទូលកាត់ឡើងថា: "លោកនាយក ! ខ្ញុំឃើញស្រីដែលបានយកដង្វាយកាន់ទៅយ៉ាងសម្បើម មកថ្វាយខ្ញុំពីប៉ុន្មានខែមុន អញ្ជើញមកក្នុងទីនេះដែរ។ ចូរលោកអញ្ជើញគាត់មកសិន ។ លោកនឹងថ្លែងសេចក្តីរាយការណ៍លោកប្រាប់ខ្ញុំម្តងទៀត នៅពេលដែលខ្ញុំបានស្តាប់អ្នកស្រីនោះនិយាយរួច" ។ លោកនាយករដ្ឋមន្ត្រីក្រឡេកភ្នែកតម្រង់ទៅផ្លូវចូលព្រះរាជរោង ក៏បានឃើញម្តាយអាឡាដាំងមែន, លោកក៏ប្រាប់ទៅនាយទ្វារបាល ដើម្បីទៅហៅគាត់ឱ្យអញ្ជើញចូលមក ។

ម្តាយអាឡាដាំងក៏ចូលទៅដល់ទៀបជើងរាជបល្ល័ង្ក ហើយលុតជង្គង់ឱនតាមទម្លាប់ ។ លុះគាត់ងើបឡើង ព្រះបាទស៊ុលតង់ក៏ទ្រង់មានព្រះបន្ទូលសួរអំពីបំណងរបស់គាត់ៗក៏ទូលឡើងថា: "បពិត្រព្រះសម្មតិទេព! ខ្ញុំម្ចាស់មកនេះ ជាតំណាងអាឡាដាំងកូនប្រុសខ្ញុំម្ចាស់ដើម្បីទូលព្រះករុណាថ្លៃវិសេសថា ពេលវេលា៣ខែ ដែលព្រះអង្គទ្រង់បានសន្មតតាមសេចក្តីស្នើរបស់ខ្ញុំម្ចាស់នោះ។ឥឡូវត្រូវកន្លងផុតហើយហេតុនេះខ្ញុំម្ចាស់មកទូលព្រះអង្គ ដើម្បីឱ្យល្អងធូលីព្រះបាទទ្រង់ ជ្រាបនូវរឿងនេះ" ។

ព្រះបាទស៊ុលតង់ ដែលបានកំណត់ពេល ៣ខែថា នឹងឆ្លើយតប

សេចក្ដីទូលស្នើរបស់ម្ដាយអាឡាដាំងនោះ, កាលព្រះអង្គទតឃើញម្ដាយអាឡាដាំងនៅលើកដំបូង,ព្រះអង្គឥតទ្រង់ស្មានថា ម្ដាយអាឡាដាំងមកនេះ ដើម្បីនិយាយស្នើព្រះអង្គអំពីរឿងរៀបអាពាហ៍ពិពាហ៍បុត្រគាត់នឹងព្រះរាជបុត្រីព្រះអង្គឡើយ ។ ពីព្រោះខុសឋានៈគ្នាឆ្ងាយណាស់ ព្រះអង្គទ្រង់យល់ផ្សេងទៅវិញថាគាត់មកនេះ ព្រោះតែគាត់មានសភាពក្រលំបាកក្នុងការចិញ្ចឹមជីវិតទេ ។ លុះម្ដាយអាឡាដាំងទូលស្នើនូវរឿងនេះយ៉ាងបង្ហំដូច្នេះ ព្រះអង្គទ្រង់បែបស្ងាក់ស្ទើរក្នុងព្រះទ័យជាក្រៃលែងពុំអាចឆ្លើយតបទៅគាត់នោះវិញភ្លាមបានឡើយ ។ ទើបព្រះអង្គទ្រង់ងាកទៅប្រឹក្សានឹងលោកនាយករដ្ឋមន្ត្រី ដោយមានព្រះបន្ទូលថា ព្រះអង្គពិបាកនឹងសម្រេចនូវរឿងអាពាហ៍ពិពាហ៍ជា-មួយនឹងមនុស្សដែលព្រះអង្គឥតទ្រង់បានស្គាល់ផងសោះ ហើយដែលព្រះអង្គទ្រង់ស្មានថា ទ្រព្យសម្បត្តិអ្នកនោះទៀតក៏អន់ថយជាក្រៃ-លែង ។

លោកនាយករដ្ឋមន្ត្រី ក៏ឥតរួញរាចិត្ត ទើបទូលថ្វាយយោបល់ដល់ព្រះបាទស៊ុលតង់ដូចតទៅនេះ : “សូមទូលព្រះករុណាថ្លៃវិសេសទូលព្រះបង្គំមានមធ្យោបាយមួយ សម្រាប់ជួយដោះស្រាយកុំឱ្យការនេះបានសម្រេច ហើយមធ្យោបាយនេះទោះបីអាឡាដាំងក៏ពុំអាចខឹងកើតដែរ គឺសូមព្រះអង្គទ្រង់បង្គាប់ថ្លៃបណ្ណាការឱ្យច្រើនលើសពីទ្រព្យសម្បត្តិ ដែលអាឡាដាំងមាន ហើយបើប្រសិនជាវារកបាន ក៏



វរកបានពុំគ្រប់ឡើយ ។ មធ្យោបាយនេះ គឺធ្វើឱ្យអាឡាដាំងប្រកែកពុំហ៊ានទទួល ល្អជាជាងព្រះអង្គមានព្រះរាជបន្ទូលឱ្យវាខឹង ធ្វើដូច្នេះវានឹងដឹងថានេះមកពីវាគួរមុនគិតពុំបានត្រិះរិះពិចារណាជាមុន ។

ព្រះបាទស៊ុលតង់ ក៏ទ្រង់យល់ស្របតាមយោបល់លោកនាយករដ្ឋមន្ត្រី ។ ព្រះអង្គទ្រង់ងាកទៅរកម្ដាយអាឡាដាំង រួចមានព្រះបន្ទូលថា : “អ្នកម្ដាយ ! ម្ចាស់ផែនដីទាំងឡាយត្រូវតែកាន់ពាក្យសច្ចៈជានិច្ច ឯយើងក៏បានគិតទុកជាមុនស្រេចហើយថា នឹងកាន់ខ្ជាប់នូវពាក្យរបស់យើងពីមុនមកដែរ ហើយនឹងឱ្យកូនអ្នកម្ដាយសប្បាយរីករាយដោយសារតែបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះរាជបុត្រីយើង។ ប៉ុន្តែយើងពុំអាចរៀបមង្គលការបុត្រីយើងដោយឥតបានសួរចិត្តវាជាមុនសោះនោះទេ ។ ចូរអ្នកម្ដាយត្រឡប់ទៅ ប្រាប់បុត្រអ្នកម្ដាយសិនថា យើងនឹងយល់ព្រមរៀបការកូនយើងជាមួយនឹងកូនអ្នកម្ដាយជាប្រាកដ កាលបើកូនអ្នកម្ដាយបានយកតោកមាស៤០មកថ្វាយយើងសិន ។ នៅក្នុងតាកមាសនោះត្រូវមាន របស់ពេញដូចដែលអ្នកស្រីបានយកមកថ្វាយយើងពីមុន ។ ហើយត្រូវមានអ្នកបម្រើខ្មៅគ្រប់ចំនួនតោកទូលយកមកផង ។ នៅក្រោយអ្នកបម្រើខ្មៅនោះត្រូវមានអ្នកបម្រើស ៤០នាក់នៅក្មេងៗ ហើយមានរូបរាងស្អាតបាតផងថែមទាំងស្លៀកពាក់យ៉ាងឆើតឆាយពណ្ណរាយដើរតាមក្រោយ នេះហើយជាលក្ខណៈសម្បត្តិដែលយើងបានគិតទុកថា នឹងរៀបផ្សំផ្គុំបុត្រី

យើងជាមួយនឹងបុត្រអ្នកម្ដាយ ។ ដូច្នេះ សូមអ្នកម្ដាយអញ្ជើញទៅវិញចុះចំណែកយើងៗនៅចាំទទួលដំណឹងពីអ្នកម្ដាយជានិច្ច ។

ម្ដាយអាឡាដាំងក៏ក្រាបថ្វាយបង្គំលាព្រះបាទស៊ុលតង់ត្រឡប់ទៅវិញ ។ នៅតាមផ្លូវគាត់នឹកអស់សំណើចតែម្នាក់ឯង នឹងគំនិតឆ្កួតនៃកូនគាត់ដោយនឹកក្នុងចិត្តថា : “តើកូនអញវា ទៅរកតាកមាសនឹងត្បូងថ្មគ្រប់ពណ៌ដ៏ច្រើនមហិមាដូច្នេះពីឯណាបាន? វានឹងចុះទៅនោះខ្ចប់ជិតទៅហើយ? ឯអ្នកបម្រើវិញ តើទៅរកពីណាមកបាន? គិតទៅការនេះឃើញខុសឆ្ងាយពីគំនិតវាណាស់ ឆ្ងាយដូចមេឃហើយនិងដី ដូច្នេះវាប្រាកដជានឹងខ្ញុំគេពុំខានឡើយ” ។ លុះត្រឡប់ទៅដល់ផ្ទះភ្លាមគាត់ក៏និយាយទៅកាន់បុត្រថា : “ម្ដាយសូមប្រាប់កូនថា ចូរកូនឯងឈប់នឹកនាអំពីរឿងរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងបា-ឌ្រូលប៊ូឌូរទៀតទៅ ។ តាមពិត ព្រះបាទស៊ុលតង់បានទទួលម្ដាយយ៉ាងគួរសមណាស់ហើយបើតាមស្មាន គឺព្រះអង្គបែបទ្រង់សព្វព្រះទ័យ នឹងកូនឯងច្រើន ប៉ុន្តែមកពីលោកនាយករដ្ឋមន្ត្រីតាមម្ដាយបានឃើញ លោកនិយាយទូលព្រះអង្គទាល់តែទ្រង់ផ្លាស់ព្រះរាជយោបល់ ។ កូនមុខជានឹងយល់ដូចម្ដាយដែរ នូវរឿងហេតុដែលម្ដាយនឹងនិយាយប្រាប់ឯងដូចតទៅនេះ ។ ក្រោយដែលម្ដាយបានក្រាបទូលព្រះអង្គថា ពេលវេលា ៣ ខែនោះបានកន្លងផុតទៅហើយ ហេតុនេះខ្ញុំម្ចាស់ សូមអង្វរព្រះអង្គ សូមឱ្យព្រះអង្គទ្រង់នឹកដល់ព្រះរាជឱង្ការព្រះអង្គពីពេល



មុន ។ ម្ដាយបានសង្កេតឃើញព្រះអង្គមុននឹងឆ្លើយ នូវសេចក្ដីទូលរបស់ម្ដាយទ្រង់ងាកទៅមានព្រះរាជឱង្ការជាមួយលោកនាយករដ្ឋមន្ត្រីមួយសន្ទុះ ។ ម្ដាយអាឡាដាំងនិយាយរឿងដែលគាត់បានទៅជួបនឹងព្រះបាទស៊ុលតង់និងលក្ខខណ្ឌដែលព្រះបាទស៊ុលតង់នឹងទទួលរៀបការព្រះរាជបុត្រីទ្រង់ជាមួយនឹងកូនគាត់ ប្រាប់កូនយ៉ាងសព្វគ្រប់ ។ នៅទីបញ្ចប់ គាត់បន្ថែមថា : “កូនប្រុសម្ដាយ ! ព្រះបាទស៊ុលតង់ទ្រង់ទន្ទឹងចាំទទួលចម្លើយអំពីអ្នក ប៉ុន្តែតាមម្ដាយយល់ថា ព្រះអង្គមុខជានឹងចាំទទួលដំណឹងនេះ អស់ពេលយ៉ាងយូរហើយ” ។

– ទេ ! មិនមែនយូរដូចម៉ាក់ឯងស្មាននោះទេ ( អាឡាដាំងឆ្លើយ) ហើយព្រះបាទស៊ុលតង់ទ្រង់យល់ច្រឡំហើយ បើសិនជាទ្រង់នឹកថា ព្រះរាជបង្គាប់ដ៏ធ្ងន់លើសលុបនោះ ធ្វើឱ្យខ្ញុំអស់សង្ឃឹមថានឹងបាន ព្រះនាងបាឌ្រូលប៊ូឌូរធ្វើជាភរិយា ។ ខ្ញុំព្រួយមួយតែនឹងឧបសគ្គអ្វីផ្សេងទៀត ដែលខ្ញុំពុំអាចទ្រាំបាន ឬមួយក៏ព្រះអង្គលើកកិត្តិយសព្រះបាទឱ្យខ្ពង់ខ្ពស់ជាងនេះទៅទៀត ។ ប៉ុន្តែក្នុងពេលឥឡូវនេះ ខ្ញុំសប្បាយចិត្តណាស់ វត្ថុដែលព្រះអង្គបង្គាប់នោះតិចតួចសោះ បើប្រៀបនឹងចិត្តរបស់ខ្ញុំ ដែលប្រាថ្នាចង់បានព្រះនាងនោះ ។ ដូច្នេះសូមអ្នកម្ដាយអញ្ជើញទៅរកអ្វីសម្រាប់រៀបចំម្ហូបអាហារបរិភោគថ្ងៃត្រង់ចុះ ទុកឱ្យខ្ញុំគិតការនេះឱ្យទាល់តែបានសម្រេច” ។

នៅពេលដែលម្ដាយអាឡាដាំង ចេញពីផ្ទះទៅរកម្ហូបអាហារ

អាឡាដាំងក៏ចូលទៅយកចង្កៀងមកត្រដុស ។ មួយសន្ទុះអារក្ស ក៏មកដល់និយាយទៅកាន់អាឡាដាំងដូចពេលមុនៗថា : តើលោកមានត្រូវការអ្វីបង្គាប់មកវាៗ នឹងទទួលធ្វើតាមទាំងអស់ ។ អាឡាដាំងពោលថា : ព្រះបាទស៊ុលតង់ ទ្រង់ព្រមរៀបការព្រះរាជបុត្រីព្រះអង្គជាមួយនឹងខ្ញុំ, ប៉ុន្តែជាដំបូងព្រះអង្គទ្រង់បង្គាប់ឱ្យរកតោកមាស៤០ធំហើយធ្ងន់ផង ។ ក្នុងតោកនោះត្រូវមានដាក់រុក្ខផលា ដែលមាននៅក្នុងសួនច្បារ គឺថានៅកន្លែង ដែលខ្ញុំបានយកចង្កៀង ហើយដែលអ្នកឯងនេះជាបម្រើចង្កៀងស្រាប់ ។ មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់បង្គាប់ទៀតថា ត្រូវមានអ្នកបម្រើសម្បុរខ្មៅទូលយកទៅផងនៅក្រោយអ្នកបម្រើខ្មៅនោះត្រូវមានអ្នកបម្រើសម្បុរស ៤០នាក់ មានរាងយ៉ាងសមសួន ហើយស្លៀកពាក់យ៉ាងស្អាតបាតផងដើរតាមក្រោយ ។ ដូច្នេះចូរអ្នកទៅរកជំនួននោះ មកឱ្យខ្ញុំដើម្បីខ្ញុំនឹងនាំយកទៅថ្វាយព្រះបាទស៊ុលតង់ មុនព្រះអង្គយាងចេញពីព្រះរោងជំនុំ" ។ អារក្សក៏ឆ្លើយទៅវិញថា នឹងទទួលធ្វើតាមបង្គាប់នេះមួយរំពេច រួចក៏អន្តរធានបាត់ទៅ ។ កន្លងក្រោយមកបន្តិច អារក្សក៏នាំមនុស្សបម្រើខ្មៅ ៤០នាក់មក ម្នាក់ៗទូលតោកមាសមួយមានទម្ងន់ប្រហែល២ម៉ាក់[១] ។ ក្នុងតោកនោះ មានដាក់ត្បូវពេជ្រគ្រប់បែបគ្រប់មុខ ដូចដែលបានយកទៅថ្វាយព្រះអង្គពីលើកមុនដែរ ។ តោកនីមួយៗ មានស្បៃប្រាក់

---

១- ម៉ាក់ (Marc) រង្វាស់រង្វាល់ក្លឹង្គ ។ =.....ក្រាម....គីឡូក្រាម



ប៉ាក់ឌិនមាសនៅជាយគ្រប់ពីលើ ។ អ្នកបម្រើទាំងខ្មៅក៏ដូចសមានចំនួនប្រហែលគ្នា ហើយកាន់តោកនៅដៃរៀងខ្លួន អង្គុយស្ទើរតែពេញផ្ទះអាឡាដាំង ។ ផ្ទះអាឡាដាំងមានសួនច្បារតូចមួយនៅខាងក្រោយទីធ្លាតូចមួយនៅខាងមុខ ។ អារក្សសួរទៅអាឡាដាំងថា តើលោកពេញចិត្តឬទេ? ហើយតើលោកមានការអ្វីនឹងប្រើខ្ញុំទៀតទេ? លុះអាឡា-ដាំងឆ្លើយថា គ្មានត្រូវការទៀតទេ អារក្សក៏អន្តរធានបាត់ទៅ ។

នៅពេលនោះ, ម្ដាយអាឡាដាំងក៏ត្រឡប់មកពីផ្សារវិញ ។ កាលបើគាត់ចូលទៅក្នុងផ្ទះ គាត់ក៏ភ្ញាក់ខ្លួនព្រើតដោយឃើញមនុស្សម្នានិងអីវ៉ាន់កកកុញនៅក្នុងផ្ទះ ។ លុះគាត់យកអីវ៉ាន់ដាក់នៅកន្លែងមួយហើយ គាត់លើកដៃប្រុងដោះស្បៃគ្រប់មុខចេញ, ប៉ុន្តែអាឡាដាំងស្ទុះមកឃាត់ហើយ ពោលថា: "ម៉ាក់ ! កុំឱ្យខាតពេលឱ្យសោះ, សូមម៉ាក់ត្រឡប់ទៅព្រះបរមរាជវាំងវិញ ឱ្យបានមុនពេលព្រះករុណាយាងចេញពីរោងជំនុំដើម្បីនាំយកជំនួនដែលជាតម្លៃរបស់ព្រះនាងបាឌ្រូល-ប៊ូឌួរ ដែលព្រះអង្គទ្រង់បង្គាប់ពីថ្ងៃមុនទៅថ្វាយប្រយោជន៍នឹងព្រះអង្គទ្រង់វិនិច្ឆ័យនូវការឆាប់រហ័សនឹងការទៀងទាត់របស់ខ្ញុំ ដែលហ៊ានចូលទៅចងស្ពានមេត្រីនឹងព្រះអង្គ" ។

ឥតបង្អង់ចាំឱ្យម្ដាយឆ្លើយទាន់ អាឡាដាំងក៏បើកទ្វារចំហទៅរកផ្លូវ, រៀបពួកអ្នកបម្រើឱ្យដើរជាក្បួន គឺឱ្យអ្នកបម្រើសដើរមុនអ្នកបម្រើខ្មៅដើរតាមក្រោយជាលំដាប់ៗគ្នា ហើយម្នាក់ៗ មានទូលតោក

មាសមួយ ។ លុះម្តាយចេញផុត គឺគាត់ដើរក្រោយគេបង្អស់. អាឡាដាំងក៏បិទទ្វារផ្ទះអង្គុយស្ងៀមក្នុងបន្ទប់មួយ ដោយមានសេចក្តីសង្ឃឹមថា ព្រះបាទស៊ុលតង់ក្រោយដែលទ្រង់បានទទួលជំនួន ដូចដែលព្រះអង្គទ្រង់បង្គាប់នោះ មុខជាទ្រង់ពេញចិត្តទទួលខ្លួនធ្វើជាព្រះរាជធិតុបតិពុំខាន ។

អ្នកបម្រើម្នាក់ ដែលចេញពីផ្ទះអាឡាដាំងមុនគេបង្អស់បានឃាត់អ្នកដំណើរ ដែលដើរតាមផ្លូវទាំងប៉ុន្មានឱ្យឈប់ទាំងអស់ ប្រយោជន៍ទុកផ្លូវឱ្យក្បួនដើរ ។ ទម្រាំតែក្បួនមនុស្សចំនួន៨០នាក់នេះចេញផុត គេឃើញប្រជាជនយ៉ាងកកកុញរត់មកពីគ្រប់ទិសទី ដើម្បីមើលទស្សនីយភាពដ៏ចម្លែកអស្ចារ្យនេះ ។ សម្លៀកបំពាក់នៃអ្នកបម្រើម្នាក់ៗ កាត់អស់កំណាត់ច្រើនណាស់ ហើយកំណាត់ទាំងនោះសុទ្ធតែត្បាញលាយនឹងសរសៃមាសផង ដែលអ្នកស្គាល់របស់នេះច្បាស់ឥតមានញញើតនឹងឱ្យតម្លៃរបស់នេះដល់ទៅម៉ឺនសែនឡើយ ។ សម្លៀកបំពាក់ឬកពាសមរម្យ. ទឹកមុខប្រិមប្រិយរាងរៅឯកសណ្ឋាន នៃអ្នកបម្រើនីមួយៗដំណើរមួយៗ ។ ហើយដើរឃ្លាតៗពីគ្នា ព្រមទាំងរស្មីភ្លឺចិញ្ចាចនៃគ្រឿងអលង្ការ ដែលដាំនៅជុំវិញខ្សែក្រវាត់មាសដ៏ធំ គ្រឿងឥស្សរិយយសពាក់នៅនឹងមួក ធ្វើឱ្យទស្សនិកជនទាំងឡាយកោតសរសើរស្ងប់ស្ងែងជាក្រៃលែង មើលហើយមើលទៀត ពុំចេះអស់ពុំចេះហើយ លុះត្រាតែផុតកន្ទុយភ្នែក ។ នៅប្របវិថី មានមនុស្ស



ឈរកកកុញពាសពេញ ម្នាក់ៗឥតហ៊ានដើរចេញពីកន្លែងខ្លួនឡើយ ខ្លាចគេដណ្តើមយកកន្លែង ។

ក្បួនដង្ហែនេះ ត្រូវដើរតាមវិថីជាច្រើន មុននឹងទៅដល់ទ្វារព្រះបរមរាជវាំង ជាហេតុនាំឱ្យប្រជាជនគ្រប់តំបន់គ្រប់ជាន់គ្រប់ថ្នាក់មកឈរមើលជាកសិណនៃកិច្ចដ៏ឧឡារិកក្រៃលែងនេះ ។ អ្នកបម្រើដែលដើរមុខក្បួនមនុស្សចំនួន៨០ បានទៅដល់ក្លោងទ្វារព្រះលានទីមួយ ។ ពួកនាយទ្វារបាលទាំងឡាយ ដែលបានឈរជាជួររួចជាស្រេចតាំងតែពីបានឃើញក្បួនដ៏អស្ចារ្យនេះមកជិតម្ល៉េះ ក៏សម្គាល់ជន ទីមួយនេះថាជាស្តេចផែនដីមួយព្រះអង្គ ដោយឃើញជនទាំងនោះស្លៀកពាក់យ៉ាងស្អាតបាតក្រៃលែង ។ ដូច្នោះហើយ ពួកទ្វារបាលក៏ដើរចូលទៅជិតដើម្បីនឹងឱនថើបជាយអាវខាងក្រោម ។ ប៉ុន្តែអ្នកបម្រើនោះ ដោយអារក្សបានប្រាប់ជាមុនស្រេច ក៏ឃាត់ជននោះឱ្យឈប់ ហើយពោលយ៉ាងខ្លាំងថា: យើងទាំងអស់គ្នាសុទ្ធតែជាអ្នកបម្រើ ។ ចៅហ្វាយយើងនឹងបង្ហាញខ្លួននៅពេលណាដែលមានការ ” ។

អ្នកបម្រើទីមួយ ព្រមទាំងអ្នកបម្រើឯទៀតក៏ដើរចូលទៅដល់ព្រះលានទីពីរ ដែលមានទំហំដ៏ធំទូលាយ ហើយដែលនៅកន្លែងនោះ មានសង់ព្រះរាជរោង សម្រាប់ព្រះបាទស៊ុលតង់នៅពេលជំនុំ ។ នាយទាហានទាំងឡាយដែលជាមេក្រុម សុទ្ធតែប្រដាប់ដោយសម្លៀកបំពាក់យ៉ាងស្អាតបាតក្រៃលែង ។ ប៉ុន្តែសម្លៀកបំពាក់ដ៏ស្អាតរបស់

នាយទាហានទាំងនោះត្រូវថយលម្អអស់ កាលបើអ្នកបម្រើ៨០នាក់ទូលគ្រឿងបណ្ណាការអាឡាដាំងចូលមកដល់ ។ ពេលនោះនៅក្នុងព្រះរោងជំនុំនៃព្រះបាទស៊ុលតង់ គេហាក់ដូចជាគ្មានឃើញអ្វីឱ្យត្រកុំត្រកាលត្រចះត្រចែងសោះ សូម្បីតែគ្រឿងអលង្ការ ដែលពួកមហាមន្ត្រីទាំងឡាយប្រដាប់កាយសម្រាប់ហែហមអមព្រះមហាក្សត្រនោះក៏គ្មានល្អដូចជារបស់ដែលគេយកទៅថ្វាយស្តេចនេះដែរ ។

ព្រះបាទស៊ុលតង់ កាលបើទ្រង់បានជ្រាបថា មានពួកអ្នកបម្រើជាច្រើនចូលមកដល់ ក៏ទ្រង់ត្រាស់បង្គាប់ឱ្យគេនាំចូលមក ។ ដូច្នោះហើយ បានជានៅពេលដែលពួកអ្នកបម្រើចូលទៅដល់មុខព្រះរាជរោងជំនុំការភ្លាម, គេឃើញទ្វារចូលព្រះរោងស្រឡះធេង, ពួកអ្នកបម្រើក៏ដើរចូលទៅយ៉ាងរៀបរយ, មួយពួកចូលទៅខាងស្តាំ, មួយពួកចូលទៅខាងឆ្វេងនៃព្រះបាទស៊ុលតង់ ។ លុះអ្នកបម្រើទាំងឡាយបានចូលទៅអង្គុយជារាងអឌ្ឍមណ្ឌល (ពាក់កណ្តាលវង់មូល) នៅមុខព្រះបាទស៊ុលតង់ហើយ, ពួកអ្នកបម្រើខ្មៅដាក់តោកដែលខ្លួនទូលយកទៅនោះទៅលើកម្រាលទ្រនាប់ជើង, រួចក៏លុតជង្គង់ព្រមគ្នាឱនក្បាលទៀបដីថ្វាយបង្គំព្រះមហាក្សត្រ ។ ឯពួកអ្នកបម្រើសក៏ធ្វើដូចគ្នានេះដែរ ។ លុះអ្នកបម្រើទាំងនោះងើបក្បាលឡើង, អ្នកបម្រើខ្មៅក៏បើកតោកទាំងនោះថ្វាយព្រះមហាក្សត្រទត រួចក៏ក្រោកឈរឱនដៃនៅស្ងៀមដោយធ្វើទឹកមុខយ៉ាងសុភាពរាបសា ។



នៅពេលនោះ ម្តាយអាឡាដាំងក៏ដើរចូលទៅជិតព្រះបាទស៊ុលតង់ឱនថ្វាយបង្គំរួចមានប្រសាសន៍ថា “បពិត្រព្រះករុណាថ្លៃវិសេស អាឡាដាំងបុត្រខ្ញុំម្ចាស់ក៏មិនមែនមិនដឹងថា គ្រឿងបណ្ណាការនេះមានតម្លៃអួនថយជាងកិត្តិយសព្រះនាងម្ចាស់ក្សត្រីបាឌ្រូលប៊ូឌូរនោះទេ ប៉ុន្តែបុត្រខ្ញុំម្ចាស់សង្ឃឹមថា ព្រះអង្គមុខជាទ្រង់សព្វព្រះរាជហឫទ័យពុំខាន ហើយនឹងទ្រង់ធ្វើឱ្យព្រះនាងសប្បាយព្រះទ័យផងដែរ ព្រោះបុត្រខ្ញុំម្ចាស់បានបំពេញកិច្ចការសព្វគ្រប់តាមព្រះរាជបំណងព្រះអង្គហើយ”

ព្រះបាទស៊ុលតង់ ទ្រង់ឥតបានយកព្រះទ័យទុកដាក់ស្តាប់ម្តាយអាឡាដាំងប៉ុន្មានទេ ។ ព្រះនេត្រព្រះអង្គកំពុងបាញ់ឆ្ពោះជាប់ទៅលើតោកមាសទាំង៤០ ដែលដាក់សុទ្ធតែគ្រឿងអលង្ការថ្លៃៗពេញកំពុងហូរហៀរ ហើយដែលគេពុំដែលឃើញមានផងនៅក្នុងពិភពលោកនេះ។ មិនតែប៉ុណ្ណោះ, ព្រះអង្គទ្រង់ជាប់ព្រះនេត្រទត អ្នកបម្រើ៤០នាក់ ដែលល្អលើសក្សត្រសោយរាជ្យទៅទៀត ទាំងទឹកមុខ ទាំងគ្រឿងស្លៀកពាក់ ។ វត្ថុទាំងនេះហើយ ធ្វើឱ្យព្រះអង្គទ្រង់ចាប់អារម្មណ៍ក្រៃលែង ស្ទើរតែឈប់ទតនឹងឈប់សរសើរពុំបាន ។ ហេតុនេះហើយបានជាគេសង្កេតឃើញព្រះបាទស៊ុលតង់ ទ្រង់មិនឆ្លើយតាមសេចក្តីទូលនៃម្តាយអាឡាដាំង ត្រឡប់ជាទ្រង់មានព្រះរាជឱង្ការទៅកាន់លោកនាយករដ្ឋមន្ត្រីវិញ ដែលកំពុងតែឆ្ងល់ថា តើរបស់ដ៏សម្បូណ៌ហូរហៀរនេះបានមកពីណា? “លោកនាយក ! តើលោកយល់

ដូចម្ដេចដែរ អំពីជនដែលនាំយករបស់ដ៏ថ្លៃថ្នូរ ហើយចម្លែកអស្ចារ្យមកនេះ ទាំងខ្លួនខ្ញុំ ទាំងខ្លួនលោកក៏ឥតដែលបានស្គាល់របស់ទាំងនេះសោះឡើយ តើលោកយល់ថា ជននោះមិនសមនឹងរៀបការជាមួយនឹងព្រះរាជបុត្រីខ្ញុំឬ?"។

លោកនាយករដ្ឋមន្ត្រី ទោះបីមានសេចក្ដីច្រណែននឹងឈឺចិត្តយ៉ាងណាចំពោះជនពុំស្គាល់នេះ ដែលនឹងបានឡើងឋានៈជាព្រះធិតុបតីនៃព្រះមហាក្សត្រជំនួសបុត្រលោកក៏ដោយ ក៏លោកពុំអាចហ៊ានបញ្ចេញយោបល់អ្វីជាទំនាស់ឡើយ ព្រោះលោកយល់ច្បាស់ថា៖ គ្រឿងបណ្ណាការរបស់អាឡាដាំងសមហួសពីសម ដល់ឋានៈធ្វើជាព្រះញាតិវង្សនៃព្រះមហាក្សត្រណាស់ទៅហើយ ។ ដូច្នេះ លោកនាយករដ្ឋមន្ត្រីក៏ទូលព្រះបាទស៊ុលតង់ថា៖ "សូមទូលព្រះករុណាថ្លៃវិសេស. ទូលព្រះបង្គំពុំអាចមានគំនិត យល់ទាស់កើតថា ជំនូនដ៏ថ្លៃថ្នូរនេះ មិនសមនឹងកិត្តិយស ដែលព្រះអង្គប្រុងធ្វើដល់ជននោះឡើយ ។ ទូលបង្គំហ៊ានទូលព្រះអង្គថា ជំនូននេះសមរម្យនឹងកិត្តិយសព្រះអង្គក្រៃលែងណាស់ ។ ដ្បិតទូលព្រះបង្គំឥតដែលបានឃើញនៅក្នុងពិភពលោកនេះ នូវឃ្លាំងមាសឃ្លាំងប្រាក់ឯណាដែលអាចយកមកផ្ទឹមនឹងតម្លៃព្រះនាងបានដូច្នេះនេះ ។ ពួកមន្ត្រីក្នុងព្រះបរមរាជវាំង ដែលនៅក្នុងកន្លែងជំនុំទាំងប៉ុន្មាន ក៏ទះដៃអបអរសាទរ ជាសញ្ញាឱ្យដឹងថាជនទាំងនោះ ឥតមានយោបល់ប្លែកពីលោកនាយករដ្ឋមន្ត្រីឡើយ" ។



ព្រះបាទស៊ុលតង់ ក៏ឥតទ្រង់យល់ទាស់ឡើយ ថែមទាំងទ្រង់ឥតរវល់អើពើនឹងចង់ដឹងអំពីគុណសម្បត្តិផ្សេងៗនៃអាឡាដាំងទៀតផង ដែលប្រាថ្នាចង់ធ្វើជាធិតុបតិព្រះអង្គនោះ ។ ការទតឃើញវត្ថុដ៏ច្រើនមហិមា ការរហ័សរហួនទាន់ពេលវេលាដែលអាឡាដាំងបានបំពេញតាមព្រះរាជបញ្ជា, ដោយគ្មានអំពល់កង្វល់ចិត្តបន្តិចសោះ នឹងភារកិច្ចដ៏ធ្ងន់លើសលប់ពន់ប្រមាណនេះ, បានធ្វើឱ្យព្រះបាទស៊ុលតង់ទ្រង់ជឿស៊ប់ថា អាឡាដាំងឥតមានខ្វះអ្វីនឹងបំពេញ តាមព្រះរាជបំណងព្រះអង្គឡើយ ។ ដូច្នេះ ដើម្បីនឹងប្រាប់ឱ្យម្ដាយអាឡាដាំងត្រឡប់ទៅផ្ទះវិញ ប្រកបដោយសេចក្ដីសប្បាយដូចបំណងគាត់នោះ ព្រះអង្គក៏ទ្រង់មានព្រះបន្ទូលដូចតទៅនេះ៖ "អ្នកស្រីម្ដាយ ! ចូរអ្នកម្ដាយត្រឡប់ទៅប្រាប់កូនអ្នកម្ដាយវិញចុះថា យើងចាំទទួលកូនអ្នកស្រីយ៉ាងរីករាយជាបំផុត. ហើយដរាបណា កូនអ្នកស្រីឆាប់មកទទួលផ្ទាល់ពីព្រះហស្តខ្ញុំនូវរង្វាន់ពិសេសមួយ គឺព្រះរាជបុត្រីយើងនោះដរាបនោះសេចក្ដីសប្បាយរបស់យើងក៏កាន់តែរីកធំឡើងដែរ" ។

កាលដែលម្ដាយអាឡាដាំងថយចេញទៅ ព្រះបាទស៊ុលតង់ក៏បិទពេលប្រជុំត្រឹមនោះ ។ ម្ដាយអាឡាដាំងត្រឡប់ទៅផ្ទះវិញ ប្រកបដោយសេចក្ដីសប្បាយជាក្រៃលែងជាងជនឯទៀតទាំងអស់ សប្បាយដោយយល់ថាស្ត្រីដែលមានឋានៈដូចគាត់នេះ អាចមានកូនប្រុសបានធ្វើជាព្រះធិតុបតីនៃព្រះមហាក្សត្រសោយរាជ្យ ។ នៅពេលដែលព្រះ

អង្គយាងចេញពីទីប្រជុំ ព្រះអង្គទ្រង់ត្រាស់បង្គាប់ដល់ពួកមនុស្សក្រៀវដែលនៅបម្រើបុត្រីព្រះអង្គឱ្យលើកយកតោកទាំងនេះ ទៅតំកល់ក្នុងព្រះរាជដំណាក់ព្រះអគ្គមហេសី ដើម្បីព្រះអង្គនឹងព្រះរាជអគ្គមហេសីយាងទៅទតមើលបានតាមត្រូវការ ព្រះរាជតម្រាស់នេះ ក៏ត្រូវគេប្រតិបត្តិតាមមួយរំពេចក្រោមបញ្ជាការនៃនាយមនុស្សក្រៀវ ។

ចំណែកពួកអ្នកបម្រើ៨០នាក់វិញ ក៏ត្រូវគេអញ្ជើញចូលទៅក្នុងព្រះបរមរាជវាំងដែរ ។ ក្រោយបន្តិចមក ព្រះបាទស៊ុលតង់ដែលទើបតែយាងត្រឡប់មកពីមានព្រះបន្ទូលរាប់រៀប អំពីលម្អនៃពួកអ្នកបម្រើប្រាប់នាងបាឌ្រូលប៊ូឌូរ ក៏ទ្រង់ត្រាស់បង្គាប់ឱ្យគេនាំអ្នកបម្រើទាំងនោះ មកមុខដំណាក់ ដើម្បីនឹងបានព្រះនាងទតតាមស្លាបព្រិលបង្អួច។ លុះបានទតហើយ ព្រះនាងក៏ជឿថា ព្រះបិតាឥតមានព្រះបន្ទូលពន្លើសឡើយ គឺថែមទាំងនៅខ្វះជាច្រើនកន្លែងទៀត ទើបសព្វគ្រប់តាមលម្អនៃជនទាំងនោះ ។

ពោលពីម្ដាយអាឡាដាំងវិញ គាត់ត្រឡប់មកផ្ទះប្រកបដោយទឹកមុខរីករាយ ញញឹមញញែម ជាសញ្ញាឱ្យដឹងជាមុនថា គាត់បានដំណឹងល្អមកប្រាប់កូនគាត់ហើយ។ មកដល់ គាត់ក៏ពោលប្រាប់កូនថា: “នៃកូនសម្លាញ់!កូនឯងបានសប្បាយហើយ គឺបានសម្រេចតាមបំណងកូនឯងមែន ផុយពីម្ដាយស្មានទៅវិញ ។ តែដើម្បីកុំឱ្យកូនឯងទន្ទឹងពីរឿងនេះយូរពេក. ព្រះករុណាបានទ្រង់ប្រកាសយ៉ាងឧឡារិកថា កូនឯងត្រូវបានព្រះនាងបាឌ្រូលប៊ូឌូរធ្វើជាភរិយា ។ ការប្រកាសនេះបានទទួលសេចក្ដីអបអរសាទរពីអ្នករាជការក្នុងវាំង និងព្រះញាតិវង្សទាំងអស់ ។ ឥឡូវនេះព្រះអង្គកំពុងគង់នៅចាំមើលផ្លូវឯង ដើម្បីកំណត់ថ្ងៃរៀបមង្គលការ ។ នេះជាភារៈរបស់កូនឯងត្រូវរៀបចំខ្លួនយ៉ាងណា ក្នុងការចូលទៅគាល់ព្រះមហាក្សត្រដើម្បីឱ្យសមទៅតាមព្រះទ័យព្រះអង្គ ។ ប៉ុន្តែដោយម្ដាយបានឃើញកូនឯងបំពេញកិច្ចប្រពៃក្រៃលែងមកហើយ ជាច្រើននោះ ម្ដាយជឿជាក់ថា គ្មានអ្វីដែលអាចធ្វើឱ្យកូនឯងធ្វើពុំកើតឡើយ ។ ម្យ៉ាងទៀតម្ដាយសូមប្រាប់ឯងថាព្រះបាទស៊ុលតង់ទ្រង់កំពុងគង់រង់ចាំទន្ទឹងមើលផ្លូវកូនឯងដោយសេចក្ដីរសាប់រសល់ ។ ដូច្នេះចូរកូនឯងកុំបង្អង់យូរប្រញាប់ចូលទៅគាល់ព្រះអង្គភ្លាម ។

អាឡាដាំង សោមនស្សនឹងដំណឹងនេះក្រៃពេក និយាយទៅម្ដាយវិញតែពីរបីម៉ាត់ប៉ុណ្ណោះ ក៏ដើរចូលទៅក្នុងបន្ទប់បាត់ទៅ ។ នៅទីនោះអាឡាដាំងក្រោយពីបានយកចង្កៀងដែលតែងតែជួយទុក្ខធុរៈវាពុំដែលខានមកដុសភ្លែក អារក្សក៏មកចាំទទួលធ្វើតាមបង្គាប់ភ្លាមឥតបង្អង់យូរឡើយ ។ អាឡាដាំងក៏និយាយទៅកាន់អារក្សនោះថា “ខ្ញុំហៅឯងមកនេះដើម្បីឱ្យឯងនាំយើងទៅមុជទឹកបន្តិច លុះមុជទឹករួចខ្ញុំត្រូវការឱ្យឯងរកសម្លៀកបំពាក់មួយប្រដាប់មក ឱ្យខ្ញុំស្លៀកពាក់។ សម្លៀកបំពាក់នោះ ត្រូវឱ្យល្អ សូម្បីតែព្រះមហាក្សត្រព្រះអង្គណា

ក៏ពុំដែលមានផង” ។ អាឡាដាំងនិយាយស្ទើរតែពុំទាន់ចប់ស្រួលផង អារក្សក៏ធ្វើអាឡាដាំងឱ្យទៅជាគេមើលពុំឃើញដូចខ្លួនវាដែរ រួចលើកហោះយកទៅដាក់ក្នុងបន្ទប់ទឹកមួយ ដែលក្រាលនឹងធ្វើសុទ្ធតែពីកែវថ្មយ៉ាងម៉ដ្ឋ ហើយមានពណ៌ផ្សេងៗព្រមទាំងលម្អខុសគ្នាទៀត ។ គ្មានទាំងបានឃើញថានរណាដែលបម្រើ ខ្លួនអាឡាដាំងក៏ត្រូវគេដោះសម្លៀកបំពាក់ចេញនៅក្នុងបន្ទប់ទទួលភ្ញៀវមួយយ៉ាងទូលាយ ហើយយ៉ាងស្អាតក្រៃលែងផង ។ ចេញពីបន្ទប់នោះមក គេយកទៅដាក់ក្នុងបន្ទប់ទឹកដែលមានទឹកក្តៅឧណ្ហៗល្មម ។ នៅក្នុងកន្លែងនោះ អាឡា-ដាំងត្រូវគេដុសលាងជម្រះខ្លួនសុទ្ធតែជាមួយ នឹងទឹកក្រអូបជាច្រើនមុខទៀត ។ ក្រោយពេលដែលគេនាំយុវជននេះ ឱ្យមុជទឹកគ្រប់បន្ទប់ហើយ ដើម្បីឱ្យខុសកំដៅគ្នា យុវជនក៏ចេញមក ប៉ុន្តែដើរតាមទ្វារផ្សេងពីទ្វារចូល រួចចូលក្នុងបន្ទប់ទទួលភ្ញៀវវិញ ដែលនៅទីនោះបុរសឥតឃើញសម្លៀកបំពាក់ ដែលខ្លួនដោះទុកពីមុនឡើយ។ អារក្សបានយកសម្លៀកបំពាក់ដែលអាឡាដាំងប្រាប់ពីមុនមកជំនួសវិញ ។ អាឡាដាំងកើតក្តីស្ងប់ស្ងែងជាក្រៃលែង ដោយបានឃើញលម្អសម្លៀកបំពាក់នោះ ។ បុរសក៏ចាប់យកខោ អាវនោះមកស្លៀក ដោយមានអារក្សជួយស្លៀកផង ។ នៅពេលស្លៀក បុរសក៏ជញ្ជាក់មាត់សរសើរសម្លៀកបំពាក់នោះគ្រប់កន្លែង។ លុះស្លៀកពាក់រួចអារក្ស ក៏លើកបុរសនេះយកទៅផ្ទះដាក់ក្នុងបន្ទប់ដដែលដូចដើមវិញ ។ រួចអារក្សក៏



សួរទៅអាឡាដាំងថា កើតមានការអ្វីនឹងប្រើវាទៀត ។ អាឡាដាំងក៏ឆ្លើយថា “មាន ! ខ្ញុំត្រូវការឱ្យឯងនាំសេះមួយដ៏ល្អលើសលុបដាច់ពីសេះសំណប់របស់ព្រះបាទស៊ុលតង់ទៀត ហើយសេះនោះ ត្រូវមានទ្រនាប់កែប កែបខ្សែបង្ហៀរ និងប្រដាប់ឯទៀតថ្លៃជាងម៉ឺនសែនប្រាក់។ មិនតែប៉ុណ្ណោះ ខ្ញុំសូមឱ្យឯងនាំមកជាមួយនឹងសេះ មនុស្សបម្រើ ២០នាក់ស្លៀកពាក់យ៉ាងប្រណីត ហើយត្រូវឱ្យមានដំណើររាងរហ័សរហួន ជាងអ្នកបម្រើដែលលើកជំនូនទៅលើកមុនប្រយោជន៍នឹងដើរអមសងខាងនឹងពីក្រោយខ្ញុំ ។ ហើយ២០នាក់ដូចគ្នាដើរពីរជួរនៅក្រោយខ្ញុំ។ រួចចូលឯងរកមនុស្សស្រីបម្រើ៦នាក់ទៀត ស្លៀកពាក់ស្អាតយ៉ាងហោចណាស់ ក៏ឱ្យប្រហែលនឹងភិលៀងព្រះនាងបាឌ្រូលប៊ូឌូរដែរឱ្យមកបម្រើម្តាយខ្ញុំ។ ស្រីទាំងនោះទៀត ត្រូវមានសម្លៀកបំពាក់ប្រើប្រាស់គ្រប់គ្រាន់ ប្រហែលនឹងភិលៀងព្រះបាទស៊ុលតាន ។ នៅទីបំផុតត្រូវការមាស១.០០០ដុំ ដាក់ក្នុងថង់១០ ។ នេះហើយរបស់ដែលខ្ញុំត្រូវការ ចូរឯងទៅរកមកឱ្យដោយរួសរាន់ ។

លុះអាឡាដាំងបង្គាប់រួចភ្លាម អារក្សក៏រលាយខ្លួនបាត់ទៅមួយរំពេច។ ក្រោយមក អារក្សក៏ត្រឡប់មកវិញនាំទាំងសេះ ទាំងអ្នកបម្រើ៤០នាក់ ដែល ១០នាក់ទូលថង់មួយម្នាក់ ថង់មួយៗមានដាក់មាស ១.០០០ដុំ ។ បន្ទាប់មកស្រីបម្រើ៦នាក់ ម្នាក់ៗទទួលសម្លៀកបំពាក់ផ្សេងៗគ្នា ដើម្បីយកមកជូនម្តាយអាឡាដាំង។ សម្លៀក

បំពាក់នីមួយៗ សុទ្ធតែរុំនឹងស្បៃប្រាក់ ។ មកដល់ហើយអារក្សក៏ប្រគល់របស់ទាំងនោះ ជូនទៅអាឡាដាំងទាំងអស់ ។

អាឡាដាំងក៏ចាប់យកថង់មាស ៤ហុចទៅម្តាយ ដើម្បីទុកឱ្យគាត់ចាយវាយប្រើប្រាស់តាមត្រូវការ ។ ឯថង់៦ទៀត វាទុកឱ្យអ្នកបម្រើដែលយកមកនោះកាន់ ដោយបង្គាប់ឱ្យបាចឱ្យប្រជាជនដែលមកឈរមើលខ្លួននៅតាមផ្លូវទៅកាន់ព្រះបរមរាជវាំង ។ ជនអ្នកកាន់ថង់នោះ ត្រូវដើរទៅមុខអាឡាដាំង គឺ៣នាក់នៅខាងស្តាំបីនាក់ទៀតនៅខាងឆ្វេង ។ តពីនោះមកអាឡាដាំងប្រគល់ស្រីបម្រើ៦ នាក់ជូនម្តាយដោយពោលប្រាប់គាត់ថា ស្រីបម្រើទាំងនេះ ជាស្រីបម្រើរបស់ម្តាយហើយ សូមអ្នកម្តាយមើលប្រើប្រាស់ ដូចជាចៅហ្វាយនាយផ្ទាល់របស់វាចុះ ។ ឯសំលៀកបំពាក់ ដែលស្រីនេះទូលយកមក ក៏សម្រាប់ជូនម្តាយប្រើប្រាស់ផ្លាស់ប្តូរដែរ ។

អាឡាដាំង កាលបើរៀបចំកិច្ចការរួចអស់ហើយក៏បង្គាប់ឱ្យអារក្សថយទៅរកទីកន្លែងវិញចុះ បើមានត្រូវការអ្វីទៀតចាំខ្លួនស្រែកហៅ ។ ឮដូច្នេះអារក្សក៏អន្តរធានបាត់ទៅ ។ នៅពេលនោះអាឡាដាំង គ្មានគិតអ្វីក្រៅពីប្រញាប់ប្រញាល់ចូលទៅគាល់ព្រះបាទស៊ុលតង់ឡើយ ។ វាប្រើអ្នកបម្រើម្នាក់ឱ្យរត់ទៅសួរនាយឆ្មាំទ្វារថា តើពេលណាទើបវាត្រូវបានចូលទៅថ្វាយបង្គំព្រះបាទស៊ុលតង់ ។ មិនយូរប៉ុន្មាន អ្នកបម្រើនោះក៏ត្រឡប់មកដល់វិញនាំសេចក្តីមកប្រាប់អាឡាដាំងថា ព្រះបាទស៊ុលតង់កំពុងទ្រង់គង់ចាំផ្លូវលោក ។



អាឡាដាំងក៏ឥតនៅបង្អង់ឡើយ ស្ទុះឡើងជិះសេះចរចេញទៅតាមរបៀបដូចយើងបានជម្រាបរួចមកហើយ ។ ពិតមែនតែអាឡាដាំង ពុំដែលទម្លាប់ជិះសេះម្តងណាសោះ ប៉ុន្តែមើលទៅហាក់ដូចជាស្ទាត់ជំនាញណាស់ ទុកជាពួកអ្នកជិះសេះយ៉ាងប្រសប់បំផុតក៏ពុំអាច ប្រដូចអាឡាដាំងទៅនឹងបុរសជិះសេះទៅបួសបានឡើយ ។ វេលានោះនៅតាមវិថីទាំងឡាយ គេឃើញមានប្រជាជនណែនណាន់តាន់តាប់មកឈរចោមរោមមើល ព្រមទាំងឮសូរសម្រែកស្រែកសរសើរស្ញប់ស្ញែង នឹងឱ្យពរគ្រប់កន្លែង ។ ពិសេសគឺនៅពេលដែលអ្នកបម្រើទាំង៤នាក់បានបាចព្រាចដុំមាសទៅលើ ជូនកាលទៅខាងស្តាំ ជូនកាលទៅខាងឆ្វេង ។ សម្រែកទាំងនេះ មិនមែនកើតមកតែអំពីជនដែលច្រានគ្នា ដើម្បីឱនរើសដុំមាសនោះឡើយ គឺកើតមកអំពីជនមួយពួកដែលមានឋានៈខ្ពស់ជាងជនសាមញ្ញ ហើយដែលពុំអាចអត់ទ្រាំនៅស្ងៀមពុំបញ្ចេញសេចក្តីអបអរសាទររបស់ខ្លួនចំពោះសប្បុរសចិត្ត នៃអាឡាដាំងបាន ។ អ្នកខ្លះដែលបាននឹកឃើញថា ធ្លាប់បានឃើញកាលពីក្មេង វាដើរលេងតាមផ្លូវផ្សេងៗ ដូចជាក្មេងអានាថានោះ ក៏ពេលនេះមើលអាឡាដាំងពុំស្គាល់ឡើយ ។ អ្នកខ្លះទៀត ដែលទើបតែនឹងបានឃើញអាឡាដាំងមិនជាយូរថ្ងៃប៉ុន្មានផង ក៏មើលអាឡាដាំងស្ទើរតែពុំចង់ស្គាល់ផង ដោយសារតែវាមានទឹកមុខប្លែកពីធម្មតា ។ ការប្លែកនេះ គឺបណ្តាលមកពីអានិសង្សចង្កៀងនេះឯង ព្រោះចង្កៀងទិព្វ

នេះ តែងជួយឧបត្ថម្ភរាងកាយជនដែលជាម្ចាស់ជានិច្ច ប៉ុន្តែលុះត្រាតែជននោះចេះប្រើប្រាស់ចង្កៀងផង ។ អ្នកនគរទាំងឡាយបានយកចិត្តទុកដាក់មើលរូបអាឡាដាំង ជាងអ្នកដែលដើរដង្ហែទាំងអស់ អ្នកខ្លះក៏ចំណាំបានថា ធ្លាប់ឃើញដើរពីថ្ងៃមុនជាមួយអ្នកបម្រើ ដែលលើកជំនូនទៅថ្វាយព្រះបាទស៊ុលតង់ ។ ឯពាជីសោតក៏បានពួកអ្នកដែលស្គាល់លក្ខណៈសេះជំនាញៗ សរសើរគ្រប់មាត់ទៀត ។ អ្នកដែលពោលសរសើរថា សត្វនោះល្អមែនគឺមិនមែនសរសើរដោយឃើញគ្រឿងអលង្ការផ្សេងៗ ដែលគេតុបតែងសត្វនោះទេ គឺសរសើរតាមលក្ខណៈសេះល្អ ។ ដំណឹងថា ព្រះបាទស៊ុលតង់ទ្រង់ព្រមរៀបចំព្រះរាជបុត្រីព្រះអង្គជាមួយអាឡាដាំង បានលាន់ឮរន្ទឺពេញព្រះរាជធានី ប៉ុន្តែឥតមានជនណាម្នាក់ ចង់ស្គាល់ស្រុកកំណើតទ្រព្យសម្បត្តិ ពូជពង្សវង្សត្រកូលអាឡាដាំងថា ជាមនុស្សមានឋានៈដូចម្ដេចឡើយ ព្រោះគេបានឃើញឫកពាដ៏ថ្លៃថ្នូរ នឹងការរុងរឿងរបស់អាឡាដាំងរួចស្រេចទៅហើយ ។

លុះអាឡាដាំងទៅដល់ព្រះបរមរាជវាំង ឃើញគេប្រុងប្រៀបរៀបចំទទួលខ្លួនយ៉ាងអឺកធឹក ។ កាលចូលទៅដល់ទ្វារទីពីរនៃព្រះបរមរាជវាំង អាឡាដាំងប្រុងចុះពីលើខ្នងសេះ ព្រោះលោកនាយករដ្ឋមន្ត្រីក្ដី លោកមេទ័ពនឹងលោកប្រមុខខែត្រ ដែលមានបណ្ដាសក្ដិធំៗទាំងឡាយក្ដី ក៏តែងតែចុះដើរនៅត្រង់កន្លែងនេះដែរ ប៉ុន្តែនាយ



ឆ្មាំទ្វាររក្សាព្រះអង្គ ដែលបានទទួលបង្គាប់ពីព្រះមហាក្សត្រឱ្យមករង់ចាំ ទទួលអាឡាដាំងក៏ឃាត់ពុំឱ្យចុះពីខ្នងសេះ រួចនាយឆ្មាំទ្វារនោះក៏ដើរតាមអាឡាដាំង រហូតដល់ជិតព្រះរាជរោងជំនុំការ ។ ទៅដល់ទីនោះ នាយឆ្មាំទ្វារក៏លូកដៃទៅដាក់អ្នកកំលោះពីខ្នងសេះ ។ ទោះបីអាឡាដាំងប្រកែកមិនព្រមឱ្យធ្វើដូច្នោះក៏ដោយ ក៏អាឡាដាំងពុំអាចនៅជាចៅហ្វាយលើខ្លួនឯងបានឡើយក្នុងពេលនោះ ។ ខណៈនោះពួកកងទាហានរក្សាព្រះអង្គក៏ឈរតម្រៀបគ្នាជាពីរជួរ នៅតាមផ្លូវចូលទៅកាន់ព្រះរាជរោង ។ នាយទាហានជំរាបឱ្យអាឡាដាំងដើរ ខាងស្ដាំដៃខ្លួន, រួចក្រោយដែលបាននាំអាឡាដាំងឱ្យដើរចំកណ្ដាលរបងមនុស្សនោះហើយ, មេតម្រួតក៏នាំបុរសល្អឆើតឆាយ ចូលទៅដល់ចំពោះព្រះភក្ត្រព្រះបាទស៊ុលតង់ ។ ·

លុះព្រះបាទស៊ុលតង់ទតឃើញបុរសភ្លាម ព្រះអង្គទ្រង់ស្ងើចក្នុងព្រះចិន្ដាជាខ្លាំង ដោយឃើញអាឡាដាំង ស្លៀកពាក់យ៉ាងសម្បើមអស្ចារ្យដូច្នេះ, សូម្បីតែព្រះអង្គជាព្រះមហាក្សត្រ ក៏ពុំដែលបានទ្រង់ស្លៀកពាក់យ៉ាងនោះដែរ ។ មិនតែប៉ុណ្ណោះ, ព្រះអង្គទ្រង់ស្ងប់ស្ងែងនឹងទឹកមុខដ៏ភ្លឺថ្លា រាងរៅដ៏សក្តិសមមើលទៅហាក់ដូចជាមានឫទ្ធិអំណាចដ៏ក្លៀវក្លា ខុសគ្នាឆ្ងាយស្រឡះពីសភាពនៃម្ដាយ ដែលបានចូលមកគាល់ព្រះអង្គពីថ្ងៃមុន ។ សេចក្ដីស្ងើចសរសើរនេះ ធ្វើឱ្យព្រះបាទស៊ុលតង់ទ្រង់គង់នៅស្ងៀមពុំបាន ក៏យាងចុះពីព្រះរាជបល្ល័ង្កយ៉ាង